# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de droit et des sciences Èconomiques

Royal University of law and Economics


# សារណាបញ្ចប់ការសិក្សា

# ការការពារស្របច្បាប់

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយនិស្សិតឈ្មោះ

**វ៉ានហេង ស៊ិនណាវ៉ាល់**

**ស៊ុំ ថៃវឌ្ឍនា**

សាស្ត្រាចារ្យណែនាំ

**លោកស្រី ចាំង ស៊ីណាត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា២០១៨-២០២២ទាំងពីររូប រួមមានខ្ញុំបាទឈ្មោះ វ៉ានហេង ស៊ិនណារ៉ាល់ និង ស៊ុំថៃវឌ្ឍនា។

**យើងខ្ញុំសូមគោរពលំអោនកាយវាចាចិត្ត សម្តែងនូវ មហាកតញ្ញូតាធម៌ដឹងគុណ យ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖**

- **លោកឪពុក ឃ្លោក ម៉េន**
- **លោកឪពុក រស់ យុទ្ធា៉**
- **ម្តាយ យូ វាសនា**
- **ម្តាយ ជួន ចាន់ថន**

**លោកឪពុក អ្នកម្តាយ** ដ៏មានគុណមិនអាចកាត់ថ្លៃបាននៃយើងខ្ញុំទាំងពីរ ដែលបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សាកូន ដោយចិត្តសណ្តោសប្រណី អប់រំប្រៀនប្រដៅ ប្រកបដោយ ព្រហ្មវិហារធម៌ គុណធម៌ សប្បុរសធម៌ ព្រមទាំងឱ្យកូនបានរៀនសូត្រខ្ពង់ខ្ពស់។

- **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** សកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំទាំងពីរបានសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរ។
- **សាស្ត្រាចារ្យណែនាំ ចាំង ស៊ីណាត** ដែលលោកស្រីបានយកចិត្តទុកដាក់ ពន្យល់យើងទាំងពីរ អំពីរបៀបតាក់តែង និងចំណុចខ្វះខាតរបស់ យើងជាប្រទីបបំភ្លឺផ្លូវឱ្យយើងដើរត្រូវចំគោលដៅ និងទទួលបានជោគជ័យជាស្ថាពរនៃការសរសេរសារណាបញ្ចប់ការសិក្សានេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមឧទ្ទិសស្នាដៃនេះជូនដល់ បុព្វបុរស និងអ្នកស្នេហាជាតិទាំងអស់ដើម្បី ជាការតបស្នងសងគុណ ចំពោះការលះបង់ទាំងឡាយ ដើម្បីវឌ្ឍនភាពសម្រាប់ប្រទេសជាតិ និងសូមរក្សាទុកនូវស្នាដៃនេះសម្រាប់និស្សិតជំនាន់ក្រោយៗទៀត ព្រមទាំងសាធារណៈជនទូទៅ ដើម្បីធ្វើជាឯកសារក្នុងការស្រាវជ្រាវ ដើម្បីបានជាប្រយោជន៍ក្នុងការសិក្សារៀនសូត្រអោយកាន់តែមានភាពល្អ ប្រសើរឡើង ដើម្បីលើកស្ទួយវិស័យយុត្តិធម៌របស់ប្រទេសកម្ពុជាឲ្យមានភាពល្អត្រឹមត្រូវជាងនេះថែមទៀត។

# អារម្ភកថា

ក្រោយពីបានពិភាក្សាជាមួយលោកស្រីសាស្ត្រាចារ្យណែនាំ និងបានពិចារណាយ៉ាងល្អិតល្អន់ពាក់ព័ន្ធនឹងប្រធានបទសារណា យើងខ្ញុំ បានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយដែលទាក់ទងទៅនឹងការការពារខ្លួនដោយស្របច្បាប់។ ដែលលើកយកមកចងក្រងសរសេរជាសារណា ដែលមានប្រធានបទឈ្មោះថា **ការការពារស្របច្បាប់។**

មូលហេតុដែលយើងខ្ញុំបានលើកយកប្រធានបទនេះមកសរសេរ ពីព្រោះខ្ញុំយល់ឃើញថាមនុស្សគ្រប់រូបដែលរស់នៅក្នុងសង្គមចាំបាច់ត្រូវយល់ដឹងអំពីច្បាប់ ហើយជាពិសេសគឺច្បាប់ព្រហ្មទណ្ឌតែម្តងថាតើអំពើបែបណាខ្លះដែលចាត់ទុកថាជាការការពារស្របទៅតាមច្បាប់ ហើយបុគ្គលណាខ្លះ ដែលជាជនល្មើសក្នុងរឿងព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវនូវរាល់អំពើល្មើសដែលខ្លួនបានប្រព្រឹត្តផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌផងដែរ?

ម្យ៉ាងវិញទៀតទាក់ទងនឹងបុគ្គលដែលបានប្រព្រឹត្តបទល្មើស នេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងរឿងព្រហ្មទណ្ឌ។ ដើម្បីអាចអោយសាធារណៈជន ទូទៅព្រមទាំងមន្ត្រីអនុវត្តច្បាប់ អាចយល់ដឹងកាន់តែច្បាស់អំពីបទល្មើសព្រហ្មទណ្ឌដែលច្បាប់ បានកំណត់ព្រមទាំងលក្ខខណ្ឌដែលកំណត់ថាជាជនល្មើសក្នុងរឿងព្រហ្មទណ្ឌ។ ហេតុដូច្នេះហើយ ទើបខ្ញុំបាទសម្រេចចិត្តសរសេរសារណាអំពីប្រធានបទមួយនេះ ដើម្បីទទួលបាននូវចំណេះដឹងឲ្យកាន់តែច្បាស់លាស់ និងអាចផ្តល់ជាប្រយោជន៍ ដល់និស្សិតជំនាន់ក្រោយៗទៀតព្រមទាំងសាធារណៈជនទូទៅធ្វើជាឯកសារក្នុងការស្រាវជ្រាវ ជាប្រយោជន៍ក្នុងការសិក្សារៀនសូត្រអោយកាន់តែមានភាពល្អប្រសើរ ព្រមទាំងជំរុញទៅដល់ការអប់រំ និងផ្សព្វផ្សាយ ក៏ដូចជាការបង្ការកុំឲ្យការកើតមានឡើងបទល្មើសព្រហ្មទណ្ឌកើតមានឡើងនៅក្នុងសង្គមកម្ពុជា។

ជាចុងក្រោយ ខ្ញុំបាទសូមអភ័យទោសចំពោះរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនាក្តី។ យើងខ្ញុំសូមស្វាគមន៍នូវរាល់មតិរិះគន់ ដើម្បីស្ថាបនាពីអស់លោកអ្នកគ្រប់ពេលវេលាផងដែរ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** .......... ១
**ជំពូកទី១.លក្ខខណ្ឌនៃការការពារស្របច្បាប់** .......... ៥
១.១ ស្ថានភាពនៃការការពារខ្លួនស្របច្បាប់ .......... ៦
១.១.១. ការការពារអ្នកដទៃ .......... ៧
១.១.២. ការការពារទ្រព្យសម្បត្តិ .......... ៨
១.២. មធ្យោបាយក្នុងការការពារខ្លួនស្របច្បាប់ .......... ៨
១.២.១. ការប្រើប្រាស់សមត្ថភាពផ្ទាល់ខ្លួន .......... ៩
១.២.២. ការប្រើប្រាស់អាវុធ .......... ៩
១.៣. អំពើឈ្លានពាន .......... ១០
១.៤. កំហុសនៃការការពារ .......... ១១
១.៤.១. ការការពារហួសព្រំដែន .......... ១២
១.៤.២. ការភាន់ច្រឡំ .......... ១៣
**ជំពូកទី២.ភស្តុតាងនៃការការពារស្របច្បាប់** .......... ១៥
២.១. បន្ទុកនៃភស្តុតាង .......... ១៥
២.១.១. ធាតុផ្សំនីត្យានុកូល .......... ១៦
២.១.២. ធាតុផ្សំសត្យានុម័ត .......... ១៦
២.១.៣. ធាតុផ្សំអត្តនោម័ត .......... ១៦
២.២. មធ្យោបាយបង្ហាញភស្តុតាង .......... ១៦
២.២.១. សក្ខីភាព .......... ១៧
២.២.២. ការសារភាព .......... ១៧
២.២.៣. ការពិនិត្យគ្រប់មុខសញ្ញា .......... ១៧
២.៣. សច្ចធារណ៍នៃការការពារស្របច្បាប់ .......... ១៨
២.៣.១. ការរុញច្រានអំពើឈ្លានពាននាពេលយប់ .......... ១៩
២.៣.២. ការរុញច្រានអំពើលួច ឬ ប្លន់ .......... ១៩

**ជំពូកទី៣.អានុភាពនៃការការពារស្របច្បាប់**............................................................................................................២១
៣.១. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ............................................................................................................២១
៣.១.១. សេចក្ដីសម្រេចរបស់អយ្យការ ............................................................................................................២២
៣.១.២. សេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ ............................................................................................................២៣
៣.១.៣. សេចក្ដីសម្រេចរបស់ចៅក្រមជំនុំជម្រះ............................................................................................................២៤
៣.២. ការរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី ............................................................................................................២៥
៣.២.១. ការរួចផុតពីការទទួលខុសត្រូវលើវត្ថុ និងសត្វ............................................................................................................២៦
៣.២.២. ការរួចផុតពីការទទួលខុសត្រូវលើសកម្មភាព ............................................................................................................២៦
**សេចក្ដីសន្និដ្ឋាន**............................................................................................................២៨
**អនុសាសន៍**............................................................................................................៣០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

ជាការពិតណាស់នៅគ្រប់ប្រទេសលើសកលលោកយើងនេះ ការគ្រប់គ្រងសង្គមមួយគឺត្រូវពឹងផ្អែកលើច្បាប់។ ថ្វីត្បិតតែមានច្បាប់ជាច្រើនសម្រាប់ការពារអាយុជីវិត សិទ្ធិសេរីភាពរបស់មនុស្ស។ ហើយមនុស្សរស់នៅក្នុងទឹ្ទបផែនដីនេះត្រូវបានចាត់ទុកជាធនធានដ៏មានតម្លៃបំផុតក្នុងសង្គម ភាពសុខដុមរមនា ស្ថេរភាព ក្នុងសង្គមគឺជាចំណុចដ៏សំខាន់ដែលត្រូវបានច្បាប់ផ្សេងៗជាច្រើនការពារ។ បើទោះបីមានច្បាប់ជាច្រើនបានបង្កើតសម្រាប់ការពារអាយុជីវិត សិទ្ធិសេរីភាពរបស់មនុស្សយ៉ាងណាក្ដី។ ក៏នៅតែមានអំពើខ្លះរបស់មនុស្សពោរពេញទៅដោយគ្រោះថ្នាក់បង្កដល់អាយុជីវិត សិទ្ធិសេរីភាពរបស់មនុស្ស និងគ្រោះថ្នាក់ដល់សង្គមផងដែរ ដែលអំពើទាំងនោះច្បាប់ហៅថាបទល្មើស។ ទិដ្ឋភាពជាក់ស្ដែងនៅក្នុងសង្គមមានបណ្ដាអំពើតទល់ ឬ ការការពាររបស់មនុស្ស។ បើពិនិត្យលើរូបភាពខាងក្រៅមានរូបរាងដូចជាបទល្មើសដែល ច្បាប់ព្រហ្មទណ្ឌបានចែង ក៏ប៉ុន្តែអំពើនោះបានបំពេញតាមលក្ខខណ្ឌដែលច្បាប់ព្រហ្មទណ្ឌទទួលស្គាល់។ ទើបហេតុនេះត្រូវបានច្បាប់ចាត់ទុកថាជាអំពើមានប្រយោជន៍ដល់សង្គមជាអំពើស្របច្បាប់ ហើយជនដែលបានប្រព្រឹត្តអំពើនោះត្រូវរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

បន្ថែមពីនោះយើងឃើញថាប្រទេសកម្ពុជា យើងបានតាក់តែងនូវច្បាប់ជាច្រើន ក្នុងនោះផងដែរលិខិតបទដ្ឋានគតិយុត្តិជាតិ-អន្តរជាតិ អង្គការអន្តរជាតិបានចូលរួម ដើម្បីគ្រប់គ្រងទំនាក់ទំនង និងការការពារសិទ្ធិរបស់ពលរដ្ឋព្រមទាំងដាក់ទោសចំពោះការបំពានទៅលើសិទ្ធិទាំងនោះ ហើយត្រូវបានបង្កើតឡើង និងយកចិត្តទុកដាក់ខ្លាំងក្នុងការផ្ដល់សិទ្ធិទៅដល់ប្រជាពលរដ្ឋ គ្រប់ស្រទាប់ដល់ដែលរស់នៅលើទឹ្ទបផែនដីមួយនេះអោយទទួលបាននៅសិទ្ធិការពារស្របច្បាប់។ ជាពិសេសដើម្បីទទួលបានសិទ្ធិក្នុងការការពារស្របច្បាប់ គឺមិនមែនត្រឹមតែកំណត់ឡើងដោយច្បាប់ជាតិសម្រាប់តែប្រជាជនដែលរស់នៅក្នុងរដ្ឋសាម៉ីប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបានយកចិត្តទុកដាក់ពីសំណាក់អង្គការអន្តរជាតិផងដែរ ក្នុងការផ្ដល់សិទ្ធិក៏ដូចជាការធានាដល់ជនគ្រប់រូបរស់នៅលើសកលលោកអោយទទួលបាននៅសិទ្ធិក្នុងការការពារស្របច្បាប់។ ដោយឡែកក្នុងនោះរួមមាន សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងកតិកាសញ្ញានេះផងដែរបានបញ្ញត្តថា គ្មានជនណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬ ត្រូវរងការប៉ះពាល់ដោយបំពានទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយជនគ្រប់រូបមានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬ ការប៉ះពាល់បែបនេះ ។ គ្មានបុគ្គលណាម្នាក់ និងក្រុម ឬ រដ្ឋណាមួយអាចយកសិទ្ធិរបស់គេនេះទៅប្រើក្នុងសកម្មភាពអ្វីមួយ ឬ អនុវត្តក្នុងអំពើណាមួយដែលបណ្ដាលឱ្យមានការវិនាសដល់សិទ្ធិ និងសេរីភាពទាំងឡាយរបស់អ្នកដទៃបានឡើយ។ ម្យ៉ាងវិញទៀតគេពុំអាចយកសិទ្ធិទាំងនោះទៅប្រើហួសពីព្រំដែន

ដែលគេបានកំណត់នោះឡើយ។ ជនគ្រប់រូបមានសិទ្ធិមានជីវិតជាប់ពីកំណើត ហើយសិទ្ធិនេះត្រូវបានការពារដោយច្បាប់។ គ្មានជនណាម្នាក់ត្រូវគេប្រហារជីវិតតាមអំពើចិត្តបានឡើយ។ បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

ក្នុងនោះផងដែរសេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្សមានមាត្រាមួយចំនួនដែលកំណត់ពីសិទ្ធិសេរីភាពរបស់មនុស្ស។ មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើតគួរគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាពជាបងប្អូន។ មនុស្សគ្រប់រូបមានសិទ្ធិទទួលការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំង នឹងការញុះញង់ឱ្យមានការរើសអើង។ ការការពារខ្លួនដោយស្របច្បាប់ទាំងក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ឬ ការឆ្លើយឆ្លង ឬ ការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ។ ជនគ្រប់រូបមានសិទ្ធិទទួលការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬ ការប៉ះពាល់ទាំងនេះ។

ក្រៅពីលិខិតបទដ្ឋានអន្តរជាតិផ្សេងៗមួយចំនួន បានកំណត់អំពីសិទ្ធិក្នុងការការពារខ្លួនស្របច្បាប់ក្នុងពេលជាមួយគ្នានេះដែរ លិខិតបទដ្ឋានជាតិ ក៏បានលើកឡើងអំពីសិទ្ធ និងកាតព្វកិច្ចក្នុងការការពារខ្លួនស្របច្បាប់ផងដែរ ។ ហើយរាជរដ្ឋាភិបាលរបស់យើងបានតាក់តែងឡើងដោ យផ្អែកលើរដ្ឋធម្មនុញ្ញ និងតម្រូវជាចាំបាច់ក្នុងការទំនាក់ទំនងរវាងក្រសួងស្ថាប័នអង្គភាពរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអោយមានការឯកភាព។ នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក៏ដោយបានបញ្ញត្តទាក់ទងទៅនឹងអំពីសិទ្ធរបស់ប្រជាពលរដ្ឋដោយជនគ្រប់រូបមានសិទ្ធិរស់មានជីវិត និងមានសេរីភាពរួមទាំងមានសន្តិភាពសុខផ្ទាល់ខ្លួន។ ក្នុងនោះផងដែរច្បាប់ការពារអាយុជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ហេតុដូច្នេះប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវទទួលបានសិទ្ធិសេរីភាព នឹងការការពារខ្លួនពីការបំពានរបស់អ្នកដ៏ទៃដោយស្របច្បាប់។

ជាពិសេសក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីសិទ្ធិក្នុងការតបតទៅនឹងការឈ្លានពានពីអ្នកដ៏ទៃក្នុងគោលបំណង ដើម្បីការពារខ្លួនដោយពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ព្រមទាំងត្រូវបានកំណត់តាំងពី ក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៣ មាត្រា ១០១ ស្តីពីកិច្ចការពារជាធម្មានុរូបបានចែងថា កាលណាបើមានការចាំបាច់ត្រូវឱ្យសម្លាប់ ឬ កាប់ ឬ វាយជនណាម្នាក់ដើម្បីការពារខ្លួនឯង ឬ ការពារអ្នកដទៃដោយធម្មានុរូប អំពើសម្លាប់កាប់ ឬ វាយនោះ មិនចូលជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមទេ។ ដោយឡែកក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា ៣៣ និង ៣៤ បានបញ្ញត្តអំពីការការពារខ្លួនដោយស្របច្បាប់។ នៅក្នុងច្បាប់បច្ចុប្បន្នក៏ពុំទាន់មានការបញ្ជាក់ណាអំពីនិយមន័យច្បាស់លាស់ណាមួយដែលនិយាយទាក់ទងទៅនឹងការការពារស្របច្បាប់នោះទេ។ គឺមានតែនិយមន័យប្រហាក់ប្រហែលគ្នា

ពីសំណាក់អ្នកនីតិវិទូ និងក្នុងបណ្ដាទ្រឹស្ដីនៃប្រព័ន្ធគតិយុត្ត មួយចំនួនប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងសទ្ទានុក្រមពាក្យច្បាប់ផ្នែកព្រហ្មទណ្ឌដែលចេញ ដោយទីស្ដីការគណៈរដ្ឋមន្ត្រី បានផ្ដល់និយមន័យ " ការការពារស្របច្បាប់ " ថាជាការតបតដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមិនត្រឹមត្រូវដែលការតបតនោះមិនត្រូវបានចាត់ទុកថាជាបទល្មើស។ តាមរយៈការប្រើប្រាស់ពាក្យ ជួនកាលគេអាចប្រើប្រាស់ពាក្យថា "កិច្ចការពារជាធម្មានុរូប ជំនួសនឹងពាក្យ " ការការពារស្របច្បាប់ " ។ ក្នុងកិច្ចការស្រាវជ្រាវនេះការការពារស្របច្បាប់ ត្រូវបានប្រើដោយតាមការកំណត់សរសេររបស់ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។

- **ចំណោទបញ្ហានៃការស្រាវជ្រាវ**

ដើម្បីជាជំនួយក្នុងការបកស្រាយនូវប្រធានបទយើងខ្ញុំបានលើកនូវចំណោទបញ្ហាមួយចំនួនដែលទាក់ទងទៅនឹងការការពារស្របច្បាប់មានដូចជា៖

  - តើអ្វីជាការការពារខ្លួនស្របច្បាប់?
  - តើអំពើទាំងនេះមានចែងក្នុងច្បាប់ព្រះរាជាណាចក្រកម្ពុជាដែល ឬ ទេ?
  - តើស្ថានភាពបែបណាដែលនាំអោយមានការការពារខ្លួនស្របច្បាប់?

- **គោលបំណងនៃការស្រាវជ្រាវ**

ការសម្រេចជ្រើសរើសយកប្រធានបទនេះមកសរសេរ ព្រោះយើងខ្ញុំយល់ឃើញថាប្រធានបទនេះមានសារៈសំខាន់ណាស់ចំពោះមនុស្សគ្រប់រូប និងចំពោះសង្គមជាតិទាំងមូលពោល គឺចូលរួមចំណែកជំនួយស្មារតីក្នុងការការពារដល់អាយុជីវិត សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិរបស់មនុស្ស។

- **ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ដែនកំណត់នៃប្រធានបទនេះលាតសន្ធឹងដល់ការការពារស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៦៩ដល់បច្ចុប្បន្ន។

- **សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ**

ការជ្រើសរើសនូវប្រធានបទនេះមកធ្វើការស្រាវជ្រាវ គឺដោយសារយើងខ្ញុំចង់ស្វែងយល់ឱ្យកាន់តែច្បាស់នូវអត្ថន័យ លក្ខខណ្ឌក្នុងការទទួលបាននូវការការពារខ្លួន ដែលត្រូវបានច្បាប់ផ្តល់អោយចំពោះសារៈសំខាន់របស់ប្រធានបទនេះគឺយើងខ្ញុំចង់ធ្វើការវិភាគបកស្រាយ និងឆ្លុះបញ្ចាំងពីទស្សនៈក្នុងច្បាប់សម្រាប់ការអនុវត្តដើម្បីជាការងាយស្រួលដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត។

- **វិធីសាស្ត្រស្រាវជ្រាវ**

ចំពោះការប្រមូលទិន្នន័យឯកសារផ្សេងៗ ដែលទាក់ទងប្រធានបទនេះ ខ្ញុំបាទព្យាយាមស្រាវជ្រាវជាលក្ខណៈទូទៅនៃប្រធានបទនេះនៅតាមប្រព័ន្ធអ៊ីនធើណេត ក៏ដូចជាការសាកសួរសុំ យោបល់ពីសំណាក់សាស្ត្រាចារ្យផ្នែកច្បាប់ សិស្សច្បង មិត្តរួមការងារ និងមន្ត្រីតាមស្ថាប័នរដ្ឋមួយចំនួន។ ជាពិសេសឯកសារដែលមានលក្ខណៈជាលាយលក្ខណ៍អក្សរផ្សេងៗ។ ខ្ញុំបាទបានព្យាយាមរកតាមបណ្ណាល័យនៅក្នុងរាជធានីភ្នំពេញ តាមតូបលក់សៀវភៅ បណ្ណាគារ និងគេហទំព័រជាតិ និងបរទេសមួយចំនួនទៀត ដែលជាគ្រឹះនាំឲ្យអាចដំណើរការសរសេរសារណានេះបានដោយភាពជោគជ័យ។

- **រចនាសម្ព័ន្ធការស្រាវជ្រាវ**

សារណានេះចែកចេញជា ០៣ ជំពូក ៖

- **ជំពូកទី ០១.លក្ខខណ្ឌនៃការការពារស្របច្បាប់**
- **ជំពូកទី ០២.ភស្តុតាងនៃការការពារស្របច្បាប់**
- **ជំពូកទី ០៣.អានុភាពនៃការការពារស្របច្បាប់**

# ជំពូកទី១

# លក្ខខណ្ឌនៃការការពារស្របច្បាប់

# ជំពូកទី ១

# លក្ខខណ្ឌនៃការការពារស្របច្បាប់

ច្បាប់បង្កើតឡើង ដើម្បីគ្រប់គ្រងទំនាក់ទំនង រួមទាំងការរស់នៅរបស់មនុស្ស។ ប្រសិនបើគ្មានច្បាប់គ្រប់គ្រងទេ មនុស្សប្រាកដជារស់នៅប្រកបដោយភាពអនាធិបតេយ្យជាមិនខានឡើយ។ យ៉ាងណាមិញច្បាប់ និង មន្ត្រីអនុវត្តច្បាប់មានតួនាទីក្នុងការធានា និងស្វែងរកនូវយុត្តិធម៌ស្មើៗគ្នាសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្គមទូទៅ។ តែទោះបីជាយ៉ាងណាក៏ដោយច្បាប់ដែលបាន បញ្ញាត្តមិនអាចមានលក្ខណៈរឹតត្បិតខ្លាំងពេកនោះដែរ។ ដោយច្បាប់បានកំណត់តើអំពីអំពើដែលប្រព្រឹត្តទៅមាន ឬ គ្មានទោស។ ដើម្បីធានានូវសិទ្ធិសេរីភាពពេញលេញដល់ពួកគេ ក្នុងការទទួលបាននូវការការពារមួយដែលសមស្របទៅតាមច្បាប់បញ្ញិត្ត។ ដោយហេតុនេះនៅក្នុងជំពូកទី១នេះ យើងនឹងលើកយកនូវលិខិតបទដ្ឋាននានា ដែលទាក់ទងទៅនឹងការការពារស្របច្បាប់ព្រមទាំងលក្ខខណ្ឌ នៃការទទួលបានការការពារស្របច្បាប់មកបង្ហាញ។

ការការពារស្របច្បាប់ ជាប្រតិកម្មតបមួយដែលច្បាប់អនុញ្ញាតឱ្យជនរងគ្រោះនៃអំពើឈ្លានពានមិនត្រឹមត្រូវ ( អនីត្យានុកូល ) ធ្វើការតបតដើម្បីការពារអាយុជីវិត និងទ្រព្យសម្បត្តិ។ ច្បាប់អនុញ្ញាតឱ្យមានការការពារបូរណភាពរូបរាងកាយ និងទ្រព្យសម្បត្តិពីការទទួលរងគ្រោះផ្សេងៗ ដែលកើតចេញពីការឈ្លានពាន ( អំពើឈ្លានពាន ) ណាមួយ។ ការអនុញ្ញាតនេះចាំបាច់ណាស់ ទោះបីជាប្រតិកម្មនេះស្តែងចេញតាមរូបភាពបែបហិង្សាក៏ដោយ ក៏ត្រូវតែស្ថិតនៅក្នុងលក្ខខណ្ឌដែលច្បាប់ព្រហ្មទណ្ឌកំណត់តែប៉ុណ្ណោះ។
មាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តថា " ការការពារស្របច្បាប់" ដូចតទៅ៖

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួនការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខ និងការឈ្លានពានមួយដែលមិនត្រឹមត្រូវ
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។[1]

## • ការឈ្លានពានមួយដែលមិនត្រឹមត្រូវ

បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិដែលប្រឈមមុខ និងការឈ្លានពានមួយដែលមិនត្រឹមត្រូវ មានន័យថាត្រូវមានការឈ្លានពានជាមុនសិន។ គួរបញ្ជាក់ដែរថាអំពើឈ្លានពាននោះ គឺត្រូវតែជាការបំពានដែលច្បាប់ បានកំណត់ដែរថាជាបទល្មើស បើទោះបីជាអំពើបំពាននោះកើតចេញពីអនីតិជន ឬ ជនវិបល្លាសស្មារតីក៏ដោយ។

[1] មាត្រា ៣៣ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

- **បទល្មើស និងការឈ្លានពានត្រូវតែកើតឡើង ក្នុងពេលជាមួយគ្នា**

លក្ខខណ្ឌមួយផ្សេងទៀត គឺបទល្មើស (ការតបត) និងអំពើឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា។ លក្ខខណ្ឌនេះមិនសូវស្មុគស្មាញពេកទេ ព្រោះការតបតក្រោយពេលបទល្មើស ត្រូវបានបញ្ចប់ គឺមិនមែនជាការការពារស្របច្បាប់ទេ តែវាបែរជាក្លាយទៅជាអំពើសងសឹកទៅវិញ ឬ ជាទ្រឹស្តីគេហៅថា "ការការពារស្របច្បាប់ហួសពេលកំណត់" ។ ម្យ៉ាងវិញទៀតការតបតក៏មិនអាចធ្វើមុនពេលមានអំពើឈ្លានពានបានដែរ បើពុំនោះទេវានឹងក្លាយជាការប្រព្រឹត្តបទល្មើសទៅវិញ ហើយជនដែលប្រព្រឹត្ត ឬ ការពារហួសដែនកំណត់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះមុនពេលដែលមានអំពើឈ្លានពាន និងក្រោយអំពើឈ្លានពាន គឺគ្មានគ្រោះថ្នាក់នោះទេ ឬ ហៅម្យ៉ាងទៀតថាគ្មានការចាំបាច់ ឬ គ្មានភាពបន្ទាន់បង្ខំក្នុងការការពារ។ និយាយឱ្យខ្លីគ្រោះថ្នាក់បានបញ្ចប់ ឬ អំពើឈ្លានពានបានបញ្ចប់ ឬ គ្មានគ្រោះថ្នាក់ដូចនេះសិទ្ធិ នៃការការពារខ្លួនស្របច្បាប់ដែលអនុញ្ញាតដោយច្បាប់ក៏ត្រូវរលត់ដែរ។

- **សមាមាត្ររវាងអំពើឈ្លានពាន និងការតបត**

បន្ទាប់ពីបញ្ចប់ការរៀបរាប់នូវលក្ខខណ្ឌទាំងពីរខាងលើ លក្ខខណ្ឌចុងក្រោយដែលចម្បង មួយទៀតនៃការការពារស្របច្បាប់គឺ មធ្យោបាយដែលប្រើប្រាស់ត្រូវតែសមាមាត្រទៅនឹងទំហំគ្រោះថ្នាក់នៃអំពើឈ្លានពាន។ រវាងមធ្យោបាយការពារដែលយកមកប្រើប្រាស់ និងទម្ងន់នៃអំពើឈ្លានពាននៅទីនេះ វាជាផលវិបាកដោយផ្ទាល់នៃភាពចាំបាច់នៃការការពារ។ យើងសូមធ្វើការបញ្ជាក់ម្តងទៀតថា ទ្រព្យសម្បត្តិមិនអាចយកមកប្រៀបធៀបជាមួយជីវិតមនុស្សបានទេ។ នៅត្រង់ចំណុចនេះ យើងអាចនិយាយបានថា ការការពារជីវិតមនុស្សគួរតែមានលក្ខខណ្ឌតឹងរឹងជាងការការពារទ្រព្យសម្បត្តិ។ ភាពគ្មានសមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន គឺជាការទទួលខុសត្រូវ។ ដូចនេះការការពារណាដែលគ្មានសមាមាត្ររវាងមធ្យោបាយការពារខ្លួន និងអំពើឈ្លានពាននោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។[2]

### ១.១. ស្ថានភាពនៃការការពារខ្លួនស្របច្បាប់

ការការពារខ្លួនដោយស្របច្បាប់ ស្ថិតក្នុងស្ថានភាពបីយ៉ាងគឺ ការការពារខ្លួន ការការពារអ្នកដទៃ និងការការពារទ្រព្យសម្បត្តិ។ ច្បាប់បានបញ្ញត្តអំពីការការពារស្របច្បាប់ គឺជាសិទ្ធិរបស់ពលរដ្ឋដែលអាចធ្វើសកម្មភាពសំដៅដល់ ការការពារប្រយោជន៍របស់រដ្ឋ ផលប្រយោជន៍សង្គម ឬ ផលប្រយោជន៍បុគ្គល។

[2] វចនានុក្រមសម្តេចសង្ឃរាជ ជួនណាត ដែលចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

បទបញ្ញត្តស្តីពី ការការពារស្របច្បាប់ក្នុងក្រមព្រហ្មទណ្ឌ គឺមានអត្ថន័យសំខាន់ក្នុងការបំផុសឱ្យមហាជនចូលរួមក្នុងសកម្មភាពទប់ស្កាត់នូវរាល់អំពើដែលបង្កឱ្យមានអន្តរាយដល់ទំនាក់ទំនងសង្គម។[3]

**ឧទាហរណ៍ជាក់ស្តែង**: **ក្រុងព្រះសីហនុ៖** គ្រាន់តែខ្វះលុយ២០០រៀល កើតជាជម្លោះ ទាស់សម្តី រវាងស្រ្តីភេទទី៣ និងអ្នកដឹកជញ្ជូនអាហារ ក្លាយជាហិង្សា ឈានទៅដល់ការដោះស្បែកជើងវាយក្បាល និងប្រទាញប្រទង់ រហូតរបូតសម្លៀកបំពាក់ ផ្អើលពេញផ្លូវ នៅវេលាម៉ោង ៩ និង៣០នាទីយប់ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ទីតាំងស្ថិតនៅតាមបណ្តោយផ្លូវ ឯករាជ្យ (ជិតតុលាការចាស់) ស្ថិតក្នុងសង្កាត់៤ ខេត្តព្រះសីហនុ។

យោងតាមប្រភពព័ត៌មាន ៖ នៅមុនពេលកើតហេតុក្រុមនារីភេទទី៣ ( LADY BOY ) បានធ្វើការបញ្ជាទិញទំនិញពីក្រុមហ៊ុនដឹកជញ្ជូនមួយកន្លែង។ ភ្នាក់ងារដឹកជញ្ជូនបានយកទំនិញនោះទៅឲ្យភ្ញៀវ ( ភេទទី៣ ) នៅទីតាំងខាងលើ ខណៈកំពុងគិតលុយ ស្រាប់តែភាគីខាង ភេទទី៣ ខ្វះលុយចំនួន២០០រៀល ទើបក្លាយទៅជាការតវ៉ាមិនត្រូវរ៉ូវគ្នា ឈានដល់ការទប់អារម្មណ៍មិនជាប់ ទើបភាគីខាង ភេទទី៣ ប្រើហិង្សារទៅលើ ភ្នាក់ងារដឹកជញ្ជូន។

តាមការបញ្ជាក់ពីភ្នាក់ងារដឹកជញ្ជូន៖ ពេលខ្លួនដឹកទំនិញឲ្យភ្ញៀវ ភាគីខាងភេទទី៣ បានខ្វះលុយចំនួន ២០០រៀល ប៉ុន្តែខ្លួនមិនបានទារនោះទេប្រហែលជា២០នាទីក្រោយស្រាប់តែភាគីខាងភេទទី៣ បានខលមកខ្លួនដោយថាខ្លួនមានខ្វះកន្ទុយ៨ពាន់រៀល តែខ្លួនបានបដិសេធ រួចនិយាយថា « អត់ទេបង មានតែបងខ្វះខ្ញុំ២០០រៀលវិញ »ភ្លាមៗនោះភាគីខាង ភេទទី៣ ក៏ហៅឲ្យមកយក ខ្លួនក៏បានទៅយកតាមសម្តី ទើបកើតហេតុខាងលើនេះតែម្តង។ ដូច្នេះអាចសន្និដ្ឋានបញ្ជាក់តាមរយះយោងតាមអង្គហេតុថា អំពើរបស់បុរស ដែលបុគ្គលិកដឹកជញ្ជូនគឺការការពារស្របច្បាប់ មិនត្រូវបានចាត់ទុក្ខជាការទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌនោះទេ អំពើរបស់គាត់គ្រាន់តែធ្វើឡើងក្នុងគោលបំណងការការពារខ្លួនតែប៉ុណ្ណោះទេ។[4]

### ១.១.១.ការការពារអ្នកដទៃ

ការការពារស្របច្បាប់ គឺមិនត្រឹមតែអាចការពារខ្លួនឯងប៉ុណ្ណោះទេ តែគេក៏អាចការពារអ្នកដទៃបានដែរ។ ដូចនេះក្នុងចំណុចនេះមានន័យថា ការការពារស្របច្បាប់មានដែនអនុវត្តមិនត្រឹមតែក្នុងការការពារខ្លួនទេ (សិទ្ធិលើបូរណភាពរូបរាងកាយ និងសិទ្ធិរស់រានមានជីវិត) ពោលការការពារស្របច្បាប់ក៏មានដែនអនុវត្តសំដៅដល់ការការពារអ្នកដទៃផងដែរ។

[3] ហ៊ី សោភា នីតិព្រហ្មទណ្ឌ។

[4] សារព័ត៌មាន ខេ ប៊ី អិន ចេញផ្សាយថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១។

**ឧទាហរណ៍:** បុរស **ក** កំពុងតែវាយ បុគ្គល **ខ** ដែលជាក្មេងសុំទានដូវយកបាយហូប។ ស្រាប់តែ បុគ្គល **គ** បានឃើញបែបនេះ គាត់ក៏រុញ បុរស **ក** ដួលទៅនឹងដីខ្ទល់បណ្ដាលអោយរងរបួស។ ក្នុងករណីនេះ បុគ្គល **គ** មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ព្រោះច្បាប់អនុញ្ញាឲ្យពលរដ្ឋគ្រប់រូបអាចការពារខ្លួន ឬ អ្នកដទៃ ។ ពីព្រោះទង្វើរបស់បុគ្គល **គ** បញ្ជាក់បានថា គ្រាន់តែចង់ការពារបុគ្គល **ខ** ដែលក្មេងទន់ខ្សោយដែលគ្មានលទ្ធភាពតបតទៅវិញទៅអំពើឈ្លានពានពោល គឺជាការការពារអ្នកដទៃដោយស្របច្បាប់។ ដូច្នេះ បុគ្គល **គ** មិនត្រូវទទួលទោសព្រហ្មទណ្ឌនោះទេ។

### ១.១.២. ការការពារទ្រព្យសម្បត្តិ

ជាការពិតណាស់ក្នុងទិដ្ឋភាពជាក់ស្ដែងក្នុងសង្គម មានពេលខ្លះដើម្បីការពារទ្រព្យសម្បត្តិកុំអោយបាត់បង់ក៏ឈានទៅដល់ ធ្វើឱ្យប៉ះពាល់ដល់បូរណភាពរាងកាយ និងពេលខ្លះរហូតដល់អាយុជីវិតមនុស្សក៏មាន។ អាយុជីវិតរបស់មនុស្សយើងមានតម្លៃណាស់ពោល គឺទោះមានទ្រព្យសម្បត្តមហាសាលក៏ដោយមិនវាយតម្លៃដូចការវាយតម្លៃរវាងទ្រព្យសម្បត្តិជាមួយនឹងប្រាក់កាសបាននោះទេ។ ត្រង់ចំណុចនេះក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនបានបញ្ជាក់ទេ គ្រាន់តែទាមទារឱ្យមានសមាមាត្ររវាងមធ្យោបាយប្រើប្រាស់ទៅនឹងទម្ងន់នៃអំពើឈ្លានពានតែប៉ុណ្ណោះ។

យើងពិនិត្យឃើញថា ការការពារត្រូវតែចាំបាច់ណាស់។ ត្រង់ចំណុច "**ចាំបាច់ណាស់**" នេះវាមានភាពពិបាកណាស់សម្រាប់កំណត់ថាតើស្ថានភាពបែបណាទើបអាចកំណត់ថាជាកិច្ចការពារចាំបាច់បំផុត។ ប៉ុន្តែបើសិនត្រូវជ្រើសរើសយកជម្រើសមួយ ដែលសមស្របបំផុតមានន័យថាជម្រើសនោះ គឺជាមធ្យោបាយតែមួយគត់ដែលល្អប្រសើរ និងមានប្រសិទ្ធភាពសម្រាប់បញ្ឈប់បទល្មើសដែលកំពុងកើតឡើង ៖

- ទទួលយកការខូចខាតដែលនឹងត្រូវកើតមានឡើង ដោយសុខចិត្តបដិសេដមិនព្រមប្រព្រឹត្តបទល្មើស
- ត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត

សូមបញ្ជាក់ដែរថា តាមវិសាលភាពនេះក្នុងការបកស្រាយបែបតឹងរឹង តាមស្មារតីនៃក្រមព្រហ្មទណ្ឌយើង គឺការការពារស្របច្បាប់ពុំមានវិសាលភាពទៅលើការការពារកិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់បុគ្គលឡើយ។

## ១.២.មធ្យោបាយក្នុងការការពារខ្លួនស្របច្បាប់

ដើម្បីតទល់ទៅនឹងអំពើឈ្លានពានមកលើខ្លួនមនុស្ស យើងគ្រប់រូបតែងតែប្រើប្រាស់នូវវិធីសាស្ត្រ ព្រមទាំងមធ្យោបាយផ្សេងៗ ក្នុងន័យធ្វើយ៉ាងណាដើម្បីឱ្យខ្លួនបានរួចផុតពីការឈ្លានពាននោះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយការតបតទៅនឹងអំពើឈ្លានពាននោះត្រូវតែស្របពេល និងសមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។ ការការពារខ្លួនអាចត្រូវបានធ្វើឡើងដោយមធ្យោបាយពីរយ៉ាង គឺការប្រើប្រាស់សមត្ថភាពផ្ទាល់ខ្លួន និងការប្រើប្រាស់អាវុធ។

### ១.២.១.ការប្រើប្រាស់សមត្ថភាពផ្ទាល់ខ្លួន

ការប្រើប្រាស់សមត្ថភាពផ្ទាល់ខ្លួន គឺជាមធ្យោបាយមួយដែលត្រូវបានប្រើប្រាស់ក្នុងការការពារខ្លួនឯង។ អ្នកដទៃ ក៏ដូចជាទ្រព្យសម្បត្តិដោយប្រើប្រាស់នូវកម្លាំងកាយ ដោយពុំមានប្រើប្រាស់នូវឧបករណ៍ ឬ មធ្យោបាយផ្សេងៗ មកជំនួយដល់ខ្លួនក្នុងការតទល់ទៅនឹងអំពើឈ្លានពាន។

**ឧទាហរណ៍:** បុរស **ក** នឹង នារី **ខ** ជាប្តីប្រពន្ធនឹងគ្នា រស់នៅជាមួយគ្នា ។ ដោយថ្ងៃមួយតាមផ្លូវបុរសជាប្តីបានលួចលេបខាយដាក់នារី **គ** ស្ថិតក្នុងផ្សារមួយកន្លែង ។ នារី **ខ** ដោយសារភ្លើងប្រចណ្ឌខ្លាំងពេកទប់ចិត្តពុំបានប្រើហិង្សាទាំងកំហឹងទៅលើនារី **គ** ។ នារី **គ** ដែលនារីរងគ្រោះបានធ្វើការតបតដោយបានវាយនារី **ខ** នោះរងរបួសវិញ។ អំពើរបស់នារី **គ** គឺជាការការពារស្របច្បាប់ពោល គឺជនម្នាក់នោះមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ពីព្រោះអំពើរបស់គាត់ គឺគ្រាន់តែជាការការពារខ្លួន។

### ១.២.២. ការប្រើប្រាស់អាវុធ

ជាធម្មតាអំពើឈ្លានពានតែងតែកើតឡើងគ្រប់រូបភាព ដូច្នេះការការពារខ្លួនក៏អាចកើតមានគ្រប់រូបភាពផងដែរ ឱ្យតែការការពារខ្លួននោះសមាមាត្រជាមួយការឈ្លានពាន។ តាមន័យនេះបញ្ជាក់ឱ្យឃើញថា ការការពារខ្លួនមិនត្រឹមតែអាចប្រើប្រាស់តែកម្លាំងកាយទេ គឺគេក៏អាចប្រើប្រាស់នូវឧបករណ៍ ឬ អាវុធផ្សេងៗទៀតបានដែរ។

អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬ ធ្វើឱ្យមានរបួស។ ក្នុងនោះផងដែរត្រូវបានចាត់ទុកដូចជាអាវុធវត្ថុដទៃទៀតដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចជា វត្ថុត្រូវបានប្រើប្រាស់សម្រាប់សំលាប់ធ្វើឱ្យមានរបួស ឬ គំរាមកំហែង។ មួយវិញទៀតការប្រើប្រាស់សត្វជាមធ្យោបាយសំរាប់សម្លាប់ និងធ្វើឱ្យមានរបួស ឬ គំរាមកំហែង ត្រូវចាត់ទុកដូចបានប្រើប្រាស់អាវុធដែរ។[5]

**ឧទាហរណ៍ជាក់ស្តែង:** យោងតាមរបាយការណ៍របស់ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានឲ្យដឹងថា នគរបាលរូបនេះស្នាក់នៅផ្ទះលេខ៥៧E1 ផ្លូវ១១៨ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ បានបាញ់ចំឈ្មោះ អ៊ូ សុជារ៉ាត់ ភេទប្រុស អាយុ ២៧ឆ្នាំ មុខរបរគ្មាន ស្នាក់នៅបន្ទប់ជួលលេខ១០៤ ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ( មានសារធាតុញៀនមេតាហ្វេតាមីន ) បណ្តាលឲ្យស្លាប់នៅកន្លែងកើតហេតុ។ សម្ភារបន្សល់ទុក កូនកាំបិតចុងស្រួច០១ដើមរបស់ជនរងគ្រោះ អាវុធខ្លីម៉ាករ៉ូឡូ០១ដើម លេខ ៣៣៨៨ ពណ៌ខ្មៅ ដងឈើ, សំបកគ្រាប់០៤គ្រាប់របស់ជនសង្ស័យ។

តាមរយៈវីដេអូកាមេរ៉ាសុវត្ថិភាព ដែលត្រូវបានគេចែកចាយបង្ហាញថា ដើមឡើយមានក្មេងទំនើង២នាក់ដេញវាយតប់គ្នានៅតាមផ្លូវ ហើយក្មេងទំនើងម្នាក់ដែលត្រូវគេដេញវាយ បានរត់ទៅឲ្យសន្តិសុខយាមធនាគារ

[5] មាត្រា ៨១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ABA (ម្នាក់ជានគរបាលខាងលើ) នៅក្បែរនោះដើម្បីជួយអន្តរាគមន៍។ ពេលនោះជនបង្កបានខឹងសម្បាយ៉ាងខ្លាំងទៅលើ មន្ត្រីនគរបាលដែលយាម និងសន្តិសុខនោះ ហើយក៏ប្រើប្រាស់ហិង្សាទៅលើនគរបាលតែម្តង។

តាមសកម្មភាពដែលបានបង្ហាញនោះ មន្ត្រីនគរបាលខាងលើមិនបានវាយតបតទៅជនបង្កនោះទេ ពោលមានតែដើរគេចតែប៉ុណ្ណោះ។ ដោយចិត្តកាន់តែខឹងសម្បាខ្លាំង ជនបង្កបានរត់ទៅយកកាំបិតដែលគេលាក់ទុកនៅក្បែរនោះ យកដេញចាក់មន្ត្រីនគរបាលទាំងកម្រោលតែម្តង បើទោះបីមន្ត្រីនគរបាលរូបនោះប្រើកាំភ្លើងដើម្បីគំរាមក៏គេមិនខ្លាចដែរ។ ដោយឃើញស្ថានភាពកាន់តែខ្លាំង មន្ត្រីនគរបាលនោះបានដកកាំភ្លើងនៅចង្កេះបាញ់ចំនួន៣គ្រាប់ ដើម្បីគំរាមជនបង្ក និងការពារខ្លួនពីការចាក់ប្រហាររបស់បុគ្គលរូបនោះ។

យោងតាមសន្និដ្ឋានបើទោះបី មន្ត្រីនគរបាលនោះបានបាញ់បណ្តាលឲ្យជនបង្កនោះស្លាប់ ក៏ពិតមែន ប៉ុន្តែតាមរយៈសកម្មភាពដែលបានរៀបរាប់ខាងលើនេះការបាញ់នេះគឺ ដើម្បីការពារខ្លួនពីការចាក់ប្រហាររបស់ជនបង្កតែប៉ុណ្ណោះ គ្មានចេតនាបាញ់ដើម្បីសម្លាប់នោះទេ ព្រោះតាំងពីកើតហេតុដំបូងមន្ត្រីនគរបាលនោះមិនវាយតបតទៅជនបង្កឡើយដូចការពារដោយប្រើអាវុធ ដើម្បីការពារអាយុជីវិតខ្លួនពីការប៉ុនប៉ងធ្វើឃាតជារឿយ។ ហើយការប្រើប្រាស់អាវុធការពារខ្លួននោះសមាមាត្រជាមួយការឈ្លានពានលើរូបរាងកាយរបស់ជនរងគ្រោះ។[6]

## ១.៣. អំពើឈ្លានពាន

ការឈ្លានពាន ត្រូវកើតឡើងមុនពេលមានការការពារ ពីព្រោះថាអំពើការពារធ្វើឡើង ដោយការចាំបាច់ដើម្បីការពារប្រឈមមុខនឹងការឈ្លានពានណាមួយ។ ការឈ្លានពានជាមុន គឺជាធាតុផ្សំចាំបាច់នៃការការពារស្របច្បាប់។ ការឈ្លានពានអាចធ្វើទៅលើទ្រព្យសម្បត្តិ ឬ រូបកាយ របស់អ្នកការពារផ្ទាល់ ឬ ទៅលើតតិយជនក៏បានដែរ។[7]

ការឈ្លានពានស្តែងឡើងតាមរយៈគ្រោះថ្នាក់ណាមួយដែលគំរាមកំហែងបុគ្គលណាម្នាក់ ទោះបីជាគ្រោះថ្នាក់នោះមិនបានបណ្តាលឱ្យបាត់បង់ជីវិតក៏ដោយ។ ក្រមព្រហ្មទណ្ឌក៏មិនបានបញ្ញត្ត ថាអំពើឈ្លានពាន ត្រូវតែជាបទល្មើសព្រហ្មទណ្ឌឡើយ គ្រាន់តែបានបញ្ជាក់ថា ត្រូវតែជាការឈ្លានពានមិនត្រឹមត្រូវតែប៉ុណ្ណោះ បានសេចក្តីថាទោះបីជាអំពើឈ្លានពានមិនមែនជាបទល្មើសព្រហ្មទណ្ឌ ក៏អាចឱ្យមានការការពារស្របច្បាប់បានដែរ។ ហេតុនេះការចាប់ខ្លួនជនណាម្នាក់ដោយអាជ្ញាធរមានសមត្ថកិច្ច មិនមែនជាការឈ្លានពានមិនត្រឹមត្រូវឡើយ ដូច្នេះការការពាររបស់ជនដែលត្រូវចាប់ខ្លួនពុំមែនជាការការពារស្របច្បាប់នោះទេ។ ដូចគ្នានេះដែរនិយោជិតដែលត្រូវបាននិយោជកបណ្តេញចេញពីការងារមិនអាចលើកសំអាងថាការបណ្តេញចេញនេះ គឺជាការឈ្លានពាន មិនត្រឹមត្រូវដែលនាំឱ្យខ្លួនមានសិទ្ធិការពារ ដោយប្រមូលយករាល់ឯកសាររបស់និយោជកមកធ្វើជា មូលដ្ឋានតាមផ្លូវ

---

[6] សារព័ត៌មាន freshnewsasia ចុះផ្សាយនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១។

[7] មាត្រា៣៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

ច្បាប់ក្នុងការទប់ទល់ នឹងការបណ្តេញចេញរបស់និយោជកបានឡើយ។ ក្នុងន័យប្រហាក់ប្រហែលគ្នានេះដែរ អំពើឈ្លានពានអ្នកដទៃនឹងនាំឱ្យមានអំពើការពារដែលអាចជាការប្រើហិង្សា ក៏ប៉ុន្តែការប្រើហិង្សាដែលអាចជាអំពើការពារនេះ មិនអាចចាត់ទុកថាជាអំពើឈ្លានពានមិនត្រឹមត្រូវនោះបានទេ និយាយម្យ៉ាងទៀតថា មិនអាចមានការការពារស្របច្បាប់លើការការពារស្របច្បាប់បានឡើយ។

**ឧទាហរណ៍:** ឪពុកបង្កើតម្នាក់បានព្យាយាមប្រព្រឹត្តអំពើហិង្សាយ៉ាងព្រៃផ្សៃទៅប្រពន្ធគាត់ ដោយជាតិស្រាចូលខ្លួននោះផង បានធ្វើអោយគាត់មានគំនិតចង់ប៉ុនប៉ងចង់ចាក់ប្រពន្ធខ្លួន។ កូនស្រីឃើញដូច្នេះក៏បានយកដបស្រាវាយអោយឪពុកសន្លប់។ យោងតាមអង្គហេតុអំពើអាចបញ្ជាក់បានថាសកម្មភាព នៃអំពើរបស់បុរស **ក** (ឪពុក) គឺជាអំពើឈ្លានពាន រីឯ នារី **ខ** (កូនស្រី) គឺអំពើស្តែងចេញចេតនាការពារ។ បុរស **ក** (ឪពុក) មិនអាចសំអាងអំពើ របស់ នារី **ខ** (កូនស្រី) ជាអំពើឈ្លានពានមកលើខ្លួនដែលអនុញ្ញាតអោយ បុរស **ក** (ឪពុក) សម្លាប់ម្តាយខ្លួននោះដែរ។

**ឧទាហរណ៍:** បន្ទាប់ពីមានទំនាស់គ្នាជាមួយបុរសម្នាក់ ហើយក្រោយមកបានឃើញបុរសម្នាក់នោះកំពុងដើរកម្សាន្តនៅមុំផ្ទះខ្លួនម្ចាស់ផ្ទះ ក៏វាយលើបុរសនោះតែម្តង ពីព្រោះតែគាត់មានការភ័យខ្លាចថា បុរសនោះនឹងវាយប្រហារមកលើខ្លួនគាត់ជាមុន ប៉ុន្តែតាមពិតបុរសជាជនរងគ្រោះពុំទាន់ទាំងមានសកម្មភាពហិង្សាណាមួយទាល់តែសោះ។ អំពើរបស់ម្ចាស់ផ្ទះ មិនមែនជាការការពារស្របច្បាប់នោះទេ ពីព្រោះពុំមានការឈ្លានពានយ៉ាងពិតប្រាកដកើតឡើងនៅឡើយ។

### ១.៤. កំហុសនៃការការពារ

បើទោះបីជាច្បាប់បានចែង អំពីការការពារស្របច្បាប់ក៏ពិតមែន ប៉ុន្តែការការពារនោះក៏មានព្រំដែនកំណត់របស់វាដែរ។ ប្រសិនបើការការពារនោះ មានលក្ខណៈមិនស្របទៅនឹងការកំណត់របស់ច្បាប់ទេ គឺមិនត្រូវបានចាត់ទុកជាការការពារស្របច្បាប់ឡើយហើយវានឹងក្លាយទៅជាកំហុសនៃការការពារទៅវិញ។ អំពើដែលត្រូវបានចាត់ទុកថាជាកំហុសនៃការការពារ គឺការការពារហួសព្រំដែន និងការភាន់ច្រឡំ។ ហើយការការពារត្រូវតែចាំបាច់សម្រាប់ស្រោចស្រង់ផលប្រយោជន៍ដែលត្រូវបានគំរាមកំហែង មានន័យថា ការការពារត្រូវតែជាការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ទ្រព្យសម្បត្តិ។ និយាយម្យ៉ាងទៀត ប្រតិកម្មតបតរបស់អ្នកការពារ គឺជាមធ្យោបាយតែមួយគត់ដើម្បីអាចបញ្ចៀសការឈ្លានពានបាននៅកាលៈទេសៈនៃរឿងហេតុពេលនោះ។ ក្នុងន័យនេះភាពបន្ទាន់នៃគ្រោះថ្នាក់ជាឧបសគ្គសំខាន់មួយ ដែលបានធ្វើអោយជនរងគ្រោះមិនអាចជ្រើសរើសយកការប្រើប្រាស់មធ្យោបាយផ្សេងៗទៀត

ក្រៅតែពីការប្រព្រឹត្តបទល្មើសដែលជាការតបតទៅលើ អ្នកឈ្លានពានវិញ ដូចការប្តឹងអាជ្ញាធរមានសមត្ថកិច្ច ឬ ក៏រត់គេចខ្លួនចេញពីការឈ្លានពានជាដើម។[8]

**១.៤.១. ការការពារហួសព្រំដែន**

ការតទល់ដែលហួសព្រំដែន មានន័យថាពុំមានភាពសមស្របច្បាស់លាស់ ជាមួយកម្រិតគ្រោះថ្នាក់នៃការរំលោភបំពាន ស្តែងឡើងជាក់ស្តែងនៅត្រង់ថាការបង្កឱ្យមានការអន្តរាយ ដល់ជនរំលោភបំពាននូវការអន្តរាយមួយក្រោមកម្រិតមួយដែលពុំចាំបាច់។ ការអន្តរាយដែលកើតឡើងចំពោះ ជនរំលោភបំពានដោយហួសហេតុ អាស្រ័យដោយអំពើរបស់អ្នកតទល់បង្កឡើង ឬ បានប្រើប្រាស់នូវវិធីសាស្ត្រឧបករណ៍ដែលពុំចាំបាច់ក្នុងទិដ្ឋភាពជាក់ស្តែងដែលកំពុងមាន អំពើរំលោភបំពាន និងមានការតទល់ ដូចជាការប្រើប្រាស់នូវអាវុធតទល់នឹងអំពើរំលោភបំពានដែលពុំមានចរិតគ្រោះថ្នាក់ធ្ងន់ធ្ងរជាដើម។

មធ្យោបាយការពារដែលបានប្រើប្រាស់ ត្រូវតែឆ្លើយតបទៅតាមសភាពធ្ងន់ធ្ងរនៃការឈ្លានពានមិនត្រឹមត្រូវ។ ជាការពិតការវាយតម្លៃអំពីវិសមាមាត្រនៃមធ្យោបាយការពារខ្លួន និងទម្ងន់នៃការឈ្លានពាន គឺអាស្រ័យទៅតាមករណីនីមួយៗ ដូចជា កាលៈទេសៈ ឬ បុគ្គលិកលក្ខណៈរបស់អ្នកដែលទទួលរងនូវការឈ្លានពានជាដើម។ ហេតុដូច្នេះ ប្រសិនបើគ្រាន់តែគោលដៅដើម្បីការពារទ្រព្យសម្បត្តិតែប៉ុណ្ណោះ អ្នកការពារមិនអាចឈានដល់ថ្នាក់ទៅសម្លាប់អ្នកឈ្លានពាន មានន័យថា តម្លៃនៃទ្រព្យសម្បត្តិមិនអាចសមាមាត្រ ឬ ប្រៀបផ្ទឹមនឹងជីវិតមនុស្សបានឡើយ។[9]

នៅពេលកំណត់អំពីបញ្ហាថាមានការការពារហួសព្រំដែនច្បាប់ ឬ ទាមទារឱ្យមានការពិនិត្យលើតុល្យភាពរវាងការអន្តរាយដែលកើតមានលើជនរំលោភបំពាន និងចរិតទំហំគ្រោះថ្នាក់ នៃអំពើរំលោភបំពានដែលត្រូវបានទប់ស្កាត់កម្រិតគាបសង្កត់នៃអំពើរំលោភបំពានកម្លាំង និងលទ្ធភាពរបស់អ្នកតទល់។ ដូចដែលក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ១០៣ បានចែងថាបើអំពើដែលបានធ្វើក្នុងកិច្ចការពារជាធម្មានុរូបនេះបានបណ្តាលឱ្យមានអន្តរាយដល់អ្នកប្រហារដោយអយុត្តិធម៌នោះហួសប្រមាណពេកអ្នកតបត ដើម្បីកិច្ចការពារនោះនៅតែត្រូវទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌដែរ ក៏ប៉ុន្តែត្រង់ថាចៅក្រមត្រូវថ្លឹងការធ្ងន់ស្រាលនេះឱ្យសមទៅតាមការគួរ។

**ឧទាហរណ៍ជាក់ស្តែង**: លោកអធិការស្រុកបានបន្តថា៖ នៅមុនពេលកើតហេតុដោយ ឈ្មោះ ជឹម អ៊ុក និង ហេង ប៊ុនធឿន មានទំនាស់ពាក្យសម្តីដែលគូទំនាស់បានទាស់សំដីជាមួយគ្នា បន្ទាប់មកឈ្មោះ ហេង ប៊ុនធឿន

[8] រុន ពណ្ណារិទ្ធ និង លោកស្រី ចាំង ស៊ីណាត នីតិវិធីព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ទំព័រ៣៤១។

[9] រុន ពណ្ណារិទ្ធ និង លោកស្រី ចាំង ស៊ីណាត នីតិវិធីព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ទំព័រ ៣៤៣។

បានវ៉ៃឈ្មោះ ជឹម អ៊ុក ចំនួន ០២ដៃ ចំក្បាលលុះដល់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង១៥.០០នាទី ឈ្មោះ ហេង ប៊ុនធឿន ដែលជាគូទំនាស់ជាមួយគ្នានោះ បានចោទថាឈ្មោះ ជឹម អ៊ុក បានដុតរោងខ្លួន បន្ទាប់ ហេង ប៊ុន ធឿន ក៏ដើរចូលវាយទៅលើឈ្មោះ ជឹម អ៊ុក ជាច្រើនដៃចំមុខបណ្តាលឲ្យមានរបួសលើផ្ទៃមុខ ។ លុះដល់ម៉ោង ១៩.០០ នាទី ថ្ងៃដដែល ឈ្មោះ ជឹម អ៊ុក បានទៅយកកាំបិតខ្វែងពីផ្ទះ ខ្លួនដើរសំដៅទៅកាប់លើឈ្មោះ ហេង ប៊ុនធឿន ចំករដៃស្តាំ បណ្តាលឲ្យមានរបួស ឃើញដូចនេះ ឈ្មោះ ចែត ថា (ប្រពន្ធ) របស់ឈ្មោះ ហេង ប៊ុនធឿន បានចូលទៅឃាត់តែត្រូវ ជឹម អ៊ុក កាប់ត្រូវកំពូនដៃខាងស្តាំបណ្តាលឲ្យរបួស ។ យោងតាមការសន្និដ្ឋាន ការប្រើប្រាស់មធ្យោបាយ នៃការតតាំងគ្នា គឺមិនសមាមាត្រដែលនិយាយអំពីការពារខ្លួនដោយហួសព្រំដែនកំណត់ (ដៃ និង កាំបិត)។[10]

**១.៤.២. ការភាន់ច្រឡំ**

ការភាន់ច្រឡំ គឺជាអំពើមួយដែលអ្នកប្រព្រឹត្តបានប្រើប្រាស់អំពើនោះ ដើម្បីតទល់ទៅលើមនុស្សម្នាក់ផ្សេងទៀត ដែលខ្លួនយល់ច្រឡំថាមនុស្សនោះបានបំពានមកលើសិទ្ធិ និងកម្មសិទ្ធិរបស់ខ្លួនពីពេលមុនៗនោះ។

**ឧទាហរណ៍ជាក់ស្តែង**: បុរសម្នាក់បានទូរស័ព្ទហៅបងប្រុសបង្កើតឲ្យមកផ្ទះរបស់ខ្លួន លុះពេលបុរសជាបងជិះម៉ូតូមកដល់មិនទាន់បាននិយាយគ្នាផង ស្រាប់តែប្អូនប្រុសកំណាចបានដកកាំភ្លើងប្រហារ បងប្រុសបំណងផ្តាច់ជីវិត តែដោយសារជនរងគ្រោះមានជីវិតថ្លៃ ទើបមិនស្លាប់គ្រាន់តែរងរបួសធ្ងន់ប៉ុណ្ណោះ។ ហេតុការណ៍បាញ់សម្លាប់មនុស្សនេះបានកើតឡើង នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង៧និង១០នាទី នៅចំណុចផ្ទះជនសង្ស័យភូមិព្រែកខ្សេវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ។

ប្រភពបន្តថា មុនពេលកើតហេតុជនសង្ស័យជាមនុស្សប្រើប្រាស់គ្រឿងញៀន ហើយតែងតែឈ្លោះគ្នាជាមួយប្រពន្ធរកស៊ីលក់ផលិតផលតាមអនឡាញ ។ លុះមកដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ៤:០០ រសៀល ជនសង្ស័យបានឈ្លោះប្រកែក ជាមួយប្រពន្ធរបស់ខ្លួនទៀត ពេលនោះជនរងគ្រោះបានចូលទៅជួយសម្របសម្រួលឲ្យឈប់ឈ្លោះគ្នា តែពេលនោះជនសង្ស័យបែរជាខឹងថា ជនរងគ្រោះចេះដឹងរឿងប្តីប្រពន្ធរបស់គេចង់បំបែកបំបាក់ ប្តីប្រពន្ធគេ។ លុះមកដល់វេលាម៉ោង០៤ទៀបភ្លឺ នាថ្ងៃកើតហេតុខាងលើជនសង្ស័យបានទូរស័ព្ទហៅជនរងគ្រោះពីខេត្តកំពង់ចាម ឲ្យឡើងមកជួបនៅផ្ទះរបស់ខ្លួន នៅភូមិព្រែកខ្សេវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដើម្បីនិយាយគ្នាបន្តិច។

[10] ព័ត៌មានសន្តិសុខសង្គម CTV8 ចេញផ្សាយថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧។

ពេលនោះជនរងគ្រោះ បានជិះម៉ូតូឡើងមកជួបជនសង្ស័យតាមការណាត់ តែនៅពេលមកដល់មិនទាន់បាននិយាយអ្វីផងក៏ត្រូវជនសង្ស័យដកកាំភ្លើងខ្លីម៉ាកឡុកបាញ់ជនរងគ្រោះត្រូវចំក្រោមភ្លៀក ខាងស្ដាំធ្លាយគ្រាប់ទៅក្រោយមានរបួសយ៉ាងធ្ងន់ ហើយជនសង្ស័យបានរកបាញ់ ឪពុកក្មេក តែមិនផ្ទុះ និងប្រតាយប្រតប់គ្នា ជ្រុះកាំភ្លើងត្រូវឪពុកក្មេកយកបាន ជនសង្ស័យបានគេចរួច។[11]

[11] ព័ត៌មាន ខេ ប៊ី អិន ចេញផ្សាយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០។

# ជំពូកទី២
# ភស្តុតាងនៃការការពារស្របច្បាប់

# ជំពូកទី២
# ភស្តុតាងនៃការការពារស្របច្បាប់

ភស្តុតាងនៃការការពារស្របច្បាប់ នៅក្នុងការការពារស្របច្បាប់របស់មនុស្សការបង្ហាញភស្តុតាង គឺធ្លាក់ទៅលើស្ថាប័នអយ្យការពោល គឺមានតែស្ថាប័នអយ្យការទេដែលជាអ្នកធ្វើការថ្លឹងថ្លែងអំពីភស្តុតាង ដែលជា ឧបករណ៍ប្រើប្រាស់ក្នុងការតបតរបស់អ្នកដែលត្រូវបានគេឈ្លានពាន។ ក្នុងឱកាសជំនុំជម្រះ ស្ថាប័នអយ្យការនេះត្រូវបានចូលរួម ដើម្បីចោទប្រកាន់ពិរុទ្ធជន និងសុំឱ្យតុលាការដាក់ទោស។ បើពុំនោះទេតុលាការពុំអាចជំនុំជម្រះ ឬធ្វើការកាត់ទោសជនល្មើសបានឡើយ។ ចំណុចនេះតម្រូវឱ្យអ្នកតបតមានភារកិច្ចបង្ហាញភស្តុតាងដល់ព្រះរាជអាជ្ញា ពោលគឺ បើអ្នកឈ្លានពានគេ ប្រើដំបង អ្នកតបតអាចប្រើដំបងតបវិញ បើអ្នកឈ្លានពានគេ ប្រើកាំបិត អ្នកតបតអាចប្រើកាំបិតតបវិញ បើអ្នកឈ្លានពានគេ ប្រើកាំភ្លើង អ្នកតបតអាចប្រើកាំភ្លើងតបវិញ បើអ្នកឈ្លានពានគេ មានគ្នាចាប់ពីរនាក់ឡើង អ្នកតបតអាចមានគ្នាចាប់ពីពីរនាក់ឡើងទៅបានដូចគ្នា តែត្រូវសមាមាត្រគ្នា។ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌបានសន្មតទុកនូវករណីពីរយ៉ាងថាជាការការពារស្របច្បាប់ ពោលគឺ ជនជាប់ចោទ (អ្នកដែលលើកសំអាងពីការការពារស្របច្បាប់មិនចាំបាច់ត្រូវការស្វែងរកភុស្តុតាង ពីលក្ខខណ្ឌទាំងឡាយដែលក្រមព្រហ្មទណ្ឌបានចែងពីរការពារស្របច្បាប់ឡើយ) បានន័យថាក្រមព្រហ្មទណ្ឌសន្មតថាជននោះបានធ្វើការពារស្របច្បាប់តែម្តង។[12]

## ២.១. បន្ទុកនៃភស្តុតាង

គោលការណ៍ដ៏សំខាន់មួយក្នុងការកំណត់ពីបន្ទុកនៃភស្តុតាង គឺគោលការណ៍សច្ចធារណ៍ នៃនិរទោស ឬ ការសន្មតជាមុនថាគ្មានទោស ដែលមានចែងនៅក្នុងលិខិតតុបករណ៍អន្តរជាតិទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋធម្មនុញ្ញរបស់កម្ពុជាផ្ទាល់តែម្តងត្រង់ មាត្រា ៣៨។

សច្ចធារណ៍ នៃនិរទោសនាំមកនូវផលវិបាកដូចតទៅ ដើម្បីកំណត់ថាជនជាប់ចោទមាន ពិរុទ្ធភាពគ្រប់គ្រាន់ អ្នកចោទប្រកាន់ត្រូវរកភស្តុតាងដាក់បន្ទុក ទៅលើជនជាប់ចោទឱ្យបានធូរល្មម។ អ្នកចោទប្រកាន់គឺតំណាងអយ្យការ ដែលត្រូវស្វែងរកភស្តុតាងគ្រប់ប្រភេទទាំងអស់ ដើម្បីបង្ហាញឱ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ដែលខ្លួនបានចោទប្រកាន់មែន។ និយាយជាលក្ខណៈទូទៅ គឺថាតំណាងអយ្យការត្រូវរកភស្តុតាងពីធាតុផ្សំទាំងបីនៃបទល្មើសរួម មានធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័ត។

ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីវិញត្រូវរកភស្តុតាងបង្ហាញឱ្យឃើញពីព្យសនកម្មដែលខ្លួនទទួលរងដើម្បីអាចទទួល បាននូវសំណងការខូចខាតទាំងនោះ។[13]

[12] រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០២២ នីតិព្រហ្មទណ្ឌទូទៅ ទំព័រ៣៨៥។

[13] មាត្រា៣៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

### ២.១.១. ធាតុផ្សំនីត្យានុកូល

ធាតុផ្សំនីត្យានុកូល ឬ ធាតុច្បាប់ មានន័យថាដើម្បីកំណត់អំពើណាមួយថាជាបទល្មើសបាន លុះត្រាតែមានច្បាប់ចែងច្បាស់លាស់។ ប្រសិនបើច្បាប់ពុំបានចែងថាអំពើនេះ ឬ អំពើនោះជាបទល្មើសទេនោះ យើងមិនអាចថាជាបទល្មើសបានឡើយ។[14]មាត្រា ២១៧ និងមាត្រា ២២២ នៃក្រមព្រហ្មទណ្ឌ អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬ អនីតិសង្វាសជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀលទៅ១០លានរៀល។

### ២.១.២. ធាតុផ្សំសត្យានុម័ត

ធាតុផ្សំសត្យានុម័ត ឬ ធាតុសម្ភារៈ គឺជាអំពើប្រព្រឹត្តទាំងឡាយដែលប្រព្រឹត្តក្រោមរូបភាព សកម្មក្តី ឬ អកម្មក្តី ប៉ុន្តែវាមានចរិតគ្រោះថ្នាក់ដល់សង្គម។ ធាតុផ្សំនេះ ជាកត្តាមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាន ប្រសិនបើមនុស្សមិនប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់នោះទេ វាក៏គ្មានលទ្ធផលអាក្រក់កើតឡើងដែរ។

### ២.១.៣. ធាតុផ្សំអត្តនោម័ត

ធាតុផ្សំអត្តនោម័ត ឬ ធាតុចិត្តសាស្ត្រ គឺជាអំពើប្រព្រឹត្តមួយដែលគ្រាន់តែមានធាតុនីត្យានុកូល និងធាតុសម្ភារៈថែមទៀត បើពុំដូច្នោះទេគេមិនអាចចាត់ទុកថាជាបទល្មើសបានឡើយ។ប្រពន្ធបានប្រើអំពើហិង្សាទៅលើប្តី ពេលដែលប្តីមិនព្រមយកម៉ូតូទៅលក់។ នេះជាចេតនា ដែលប្រពន្ធប្រើហិង្សាទៅលើប្តី។[15]

## ២.២. មធ្យោបាយបង្ហាញភស្តុតាង

រាល់មធ្យោបាយបង្ហាញភស្តុតាងទាំងអស់អាចត្រូវយកមកប្រើប្រាស់ដោយភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលភស្តុតាងនីមួយៗពុំមានតម្លៃភស្តុតាងធ្ងន់ ឬស្រាលជាងគ្នានោះទេ ហើយច្បាប់ទុកលទ្ធភាពឱ្យចៅក្រមសម្រេចសេចក្តីដោយផ្អែកលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ចៅក្រម។ មធ្យោបាយបង្ហាញភស្តុតាងមាន សក្ខីភាព ការសារភាព និងការពិនិត្យគ្រប់មុខសញ្ញា។[16]

[14] មាត្រា៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[15] មាត្រា៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[16] មាត្រា៣២១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០៣០, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ២.២.១. សក្ខីភាព

សាក្សី គឺជាបុគ្គលដែលបានឃើញ ឬ បានដឹងសព្វដោយផ្ទាល់ពីអង្គហេតុទាំងឡាយដែលពាក់ព័ន្ធនឹងរឿងក្តីណាមួយ។[17]

សាក្សីមានកាតព្វកិច្ចត្រូវបង្ហាញខ្លួន តាមការកោះហៅរបស់តុលាការ។ សាក្សីត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការឆ្លើយរាយការណ៍របស់ខ្លួន។ សក្ខីកម្មភូតកុហកដែលធ្វើក្រោយពីបានស្បថនៅមុខតុលាការ ឬ នៅមុខមន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើសកម្មភាពក្នុងក្របខ័ណ្ឌ នៃដីកាចាត់ឱ្យសួរចម្លើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល ប៉ុន្តែលើកលែងឱ្យសាក្សីភូតកុហករួចផុតពីទោសប្រសិន បើសាក្សីនេះប្រែក្រឡាស់ដោយឯកឯងនូវសក្ខីកម្មរបស់ខ្លួនហើយនិយាយតែការពិតមុនសេចក្តីសម្រេចបញ្ចប់ នីតិវិធីស៊ើបសួរ ឬ នីតិវិធីជំនុំជម្រះ។[18]

### ២.២.២. ការសារភាព

ចៅក្រម ព្រះរាជអាជ្ញា និងនគរបាលយុត្តិធម៌ មានសមត្ថកិច្ចអាចសួរចម្លើយជនដែល សង្ស័យថាបានប្រព្រឹត្តបទល្មើសដោយកត់ត្រាចម្លើយនៅក្នុងកំណត់ហេតុ។ មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានឱ្យតម្លៃខ្ពស់ទៅលើការសារភាពនោះទេ។ មាត្រា ៣២១ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាត់ទុកការសារភាព ជាប្រភេទមួយនៃភស្តុតាងដូចភស្តុតាងដទៃទៀតដែរ។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬ ខាងផ្លូវចិត្ត គ្មានតម្លៃជាភស្តុតាងទេ។

### ២.២.៣. ការពិនិត្យគ្រប់មុខសញ្ញា

ដើម្បីស្វែងរកការពិត ចៅក្រមត្រូវពិនិត្យគ្រប់មុខសញ្ញាទាំងអស់ ដែលមានក្នុងសំណុំរឿងដើម្បីធ្វើជាមូលដ្ឋាននៃការផ្តន្ទាទោស ឬ មិនផ្តន្ទាទោស។ ក្នុងន័យខាងលើនេះ ចៅក្រមស៊ើបសួរ ឬ ចៅក្រមជំនុំជម្រះពិនិត្យទៅលើកំណត់ហេតុ របស់មន្ត្រីនគរបាលយុត្តិធម៌ កោសល្យវិច្ច័យរបស់អ្នកជំនាញ វត្ថុតាងនានាដែលមន្ត្រីនគរបាលយុត្តិធម៌ប្រគល់ឱ្យ ឬ ដែលចៅក្រមស៊ើបសួរចាត់ឱ្យប្រមែប្រមូល។ ហេតុដូច្នេះហើយទើបចៅក្រមស៊ើបសួរអាចចុះទៅពិនិត្យដល់កន្លែងកើតហេតុផ្ទាល់ ដើម្បីដឹងពីការពិតជាក់ស្តែងពីកាលៈទេសៈនៃបទល្មើស។

ការពិនិត្យទៅលើគ្រប់មុខសញ្ញា អាចឱ្យចៅក្រមឈានទៅរកការសន្និដ្ឋានមួយទៅលើអង្គហេតុដែលកើតមានពិតប្រាកដ ដោយផ្អែកទៅលើ ការពិចារណា ការប្រៀបធៀបជាដើម។ ការសន្និដ្ឋាននេះអាចត្រូវគ្នាជាមួយនឹងចម្លើយរបស់សាក្សី ជនរងគ្រោះ ឬ ជនជាប់ចោទ។

[17] វុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត នីតិព្រហ្មទណ្ឌទូទៅ ២០១២, ទំព័រ ៥៨៨។

[18] មាត្រា៥៤៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

## ២.៣. សច្ចធារណ៍នៃការការពារស្របច្បាប់

តាមរយៈការសិក្សាស្រាវជ្រាវ ក្នុងវិធានព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា យើងឃើញ ថាមានករណីមួយទៀតដែលក្នុងក្របខណ្ឌនៃការការពារស្របច្បាប់បានកំណត់ថាជាការការពារស្របច្បាប់ ហើយថាទាក់ទងជាមួយនឹងបន្ទុកនៃភស្តុតាង។

មាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌ ក៏ដូចជាក្រមព្រហ្មទណ្ឌចាស់ដែរបានសន្មតថាជាការការពារស្របច្បាប់ក្នុងករណីដូចខាងក្រោម៖

- បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ ទំលុះទម្លាយ ដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សរស់នៅ។
- បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា។[19]

ក្នុងករណីនៃសច្ចធារណ៍ នៃការការពារស្របច្បាប់ដូចមានចែងខាងលើនេះ ចារីដែលបានប្រព្រឹត្តបទល្មើសគ្រាន់តែបង្ហាញភស្តុតាងអំពីស្ថានភាពដូចមានចែងក្នុងចំណុចទី១ ឬចំណុច ទី២ នៃមាត្រា ៣៤ ជាការគ្រប់គ្រាន់ហើយ ដោយមិនចាំបាច់បង្ហាញភស្តុតាងពីលក្ខខណ្ឌនៃការការពារស្របច្បាប់ដូចមានចែងនៅមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌឡើយ។[20]

**ឧទាហរណ៍:**ដោយបន្ទាប់ពីសម្រាកពី យាមល្បាតមន្ត្រីយោធាម្នាក់ បានសម្រានលង់លក់យ៉ាងស្កប់ស្កល់នៅផ្ទះរបស់ខ្លួនរហូតដល់ពាក់កណ្ដាលអាធ្រាត ប្រហែលជាម៉ោង ២:០០ទាបភ្លឺ លឺសំឡេងក្រេកក្រកនៅក្នុងផ្ទះរបស់ខ្លួន បន្ទាប់ពីលឺសម្លេងចម្លែកនេះ គាត់បានភ្ញាក់ដឹងខ្លួនរួចកាន់កាំភ្លើងខ្លីមួយដើមដែលអង្គភាពបានផ្ដល់ទុកសំរាប់ប្រតិបត្តិលើស្ថានចាំបាច់ណាមួយយកប្រើប្រាស់ រួចដើរអង្កេតជុំវិញបរិវេណផ្ទះដោយបង្អួចត្រូវបាននរណាម្នាក់គាស់ នឹងរបើកអស់រលីង ដោយការមានសង្ស័យទៅលើជនល្មើសដែលទំលុះចូលក្នុងផ្ទះ បានបាញ់ក្នុងបណ្ដាលជនល្មើសនោះបានបង់ជីវិត។

តាមសម្មតិកម្មខាងលើនេះ អំពើប្រព្រឹត្តរបស់លោក មន្ត្រីយោធា ដែលបានប្រើប្រាស់កាំភ្លើង គឺជាបទល្មើសព្រហ្មទណ្ឌ ។ ហេតុនេះជាធម្មតា ដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះ មន្ត្រីយោធាម្នាក់នោះត្រូវរកភស្តុតាងមកបញ្ជាក់អំពី ការការពារស្របច្បាប់ដែលមានចែងនៅក្នុងមាត្រា ៣៣ នៃក្រម។ ផ្ទុយទៅវិញក្នុងករណីដែលបានកើតឡើងទៅលើមន្ត្រីយោធា ដូចខាងលើនេះ ប្រសិនបើមន្ត្រីយោធារកភស្តុតាងមកបញ្ជាក់ថាការសម្លាប់ចោរ ដោយសារតែជននោះបានចូលមកក្នុងផ្ទះរបស់ខ្លួនក្នុងពេលយប់ ដោយការគាស់ទម្លុះទម្លាយ (ជាធម្មតាភស្តុតាងនេះអាចរកបានដោយងាយស្រួល) ដោយមន្ត្រីយោធារូបនេះ មិនចាំបាច់រកភស្តុតាង

[19] មាត្រា ១០៤ ក្រមព្រហ្មទណ្ឌចាស់ ។

[20] រុន ពណ្ណរិទ្ធ និង លោកស្រី ចាំង ស៊ីណាត នីតិវិធីព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ទំព័រ ៣៤៦។

ពីលក្ខខណ្ឌនៃការការពារស្របច្បាប់ឡើយពោលគឺ ក្រមព្រហ្មទណ្ឌសន្មតថា មន្ត្រីរូបនោះបានប្រព្រឹត្តបទល្មើសក្នុងលក្ខខណ្ឌនៃការការពារស្របច្បាប់តែម្តង ។

### ២.៣.១. ការរុញច្រាននៃអំពើឈ្លានពាននាពេលយប់

បទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានអំពើឈ្លានពាននៃការចូលនៅពេលយប់ ដែលមានការកាប់គាស់ទម្លុះទម្លាយដោយហិង្សា ឬ ដោយកលល្បិចនៅកន្លែងដែលមានមនុស្សរស់នៅ។ ដូចនេះការចូលនៅពេលយប់ក្នុងកន្លែងដែលមានមនុស្សនៅតាមរយៈការប្រើប្រាស់សោរក្លែង ឬ ការគាស់ទម្លុះទម្លាយ គឺច្បាប់បានអនុញ្ញាតឱ្យម្ចាស់ ដែលរស់នៅកន្លែងនោះប្រើមធ្យោបាយទប់ទល់ ដើម្បីរុញច្រាននឹងអំពើឈ្លានពាននោះវិញ។

ការចូលដោយកាប់គាស់ទម្លុះទម្លាយ គឺជាការចូលដោយប្រើអំពើបង្ខំធ្វើឱ្យខូចខាត ឬ បំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬ របងទោះបីមានប្រភេទយ៉ាងណាក៏ដោយ។ មួយវិញទៀតត្រូវចាត់ទុកដូចជា ការចូលកាប់គាស់ទម្លុះទម្លាយដូចជា ការប្រើប្រាស់កូនសោក្លែង ការប្រើប្រាស់កូនសោដែលបាន មកដោយឧបាយកលទុច្ចរិត ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទមានដំណើរការ ដោយគ្មានការបង្ខំ ការខូចខាត ឬ ការបំផ្លិចបំផ្លាញទេ។[21]

**ឧទាហរណ៍:**មន្ត្រីយោធាម្នាក់ដែលប្តីរបស់នារីម្នាក់បាន យកកាំភ្លើងបាញ់ប្អូនប្រុសបង្កើតដែលជាសាហាយប្រពន្ធខ្លួន នៅពេលដែលបុរសជាសាហាយនោះបានប្រើសោក្លែងចូលក្នុងរបងផ្ទះ។ តាមពិតបុរសជាប្តីបានកត់សម្គាល់ច្បាស់ហើយថាពេលយប់ឡើង ប្អូនប្រុសដែលជាសាហាយតែងតែលួចចូលមកជួបជាមួយនឹង ប្រពន្ធរបស់ខ្លួនញឹកញាប់។ បុរសជាប្តីបានដឹងយ៉ាងច្បាស់ថា ម្នាក់នោះគឺជាប្អូនប្រុស តែគាត់នៅតែយកកាំភ្លើងបាញ់ដោយអះអាងថា ជាស្ថានភាពនៃការការពារស្របច្បាប់ ដោយសារមូលហេតុរុញច្រានអំពើឈ្លានពានចូលពេលយប់។ ក្នុងករណីនេះ គឺជាការប្រើប្រាស់មធ្យោបាយមានវិសមាមាត្រមិនសមរម្យ នឹងអំពើដែលឈ្លានពានដែលនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។

### ២.៣.២. ការរុញច្រានអំពើលួច ឬប្លន់

បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីការពារខ្លួន ដើម្បីប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្ត ដោយហិង្សា។[22] គួររំលឹកផងដែរថា ចំពោះសច្ចធារណ៍នៃការការពារស្របច្បាប់នេះ ពុំមានលក្ខណៈជាដាច់ខាតទេពោល គឺវានឹងត្រូវរលាយនៅពេលមានភស្តុតាងផ្ទុយ។[23] ដូច្នេះហើយទោះបីជាយើងស្ថិតក្នុងស្ថានភាពនៃការ

[21] មាត្រា៧៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[22] មាត្រា៣៤ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១១០៩/០២២,ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[23] មាត្រា៣៤ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១១០៩/០២២,ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

សន្មតថាការការពារស្របច្បាប់ក៏ដោយ ក៏ច្បាប់មិនអនុញ្ញាតឱ្យប្រើប្រាស់មធ្យោបាយតទល់ដែលមានវិសមាមាត្រជាមួយនឹងអំពើឈ្លានពានឡើយ ហើយដែលយើងបានយល់ដឹងច្បាស់ទៀត។

**ឧទាហរណ៍:**បើទោះបីមន្ត្រីយោធាម្នាក់ទទួលបានផលប្រយោជន៍ ពីសច្ចាធារណ៍នៃការការពារស្របច្បាប់មែន បន្ទាប់ពីនោះបានបាញ់សម្លាប់ បុគ្គលម្នាក់ដែលចូលគាស់ផ្ទះរបស់គាត់ ក៏ប៉ុន្តែតំណាងអយ្យការនៅតែអាចរកភស្តុតាងផ្ទុយមករំលាយសច្ចាធារណ៍នេះបានដោយ លើកឡើងពីចំណុចខ្វះខាតនៃលក្ខខណ្ឌនៃការការពារស្របច្បាប់ដែលមានចែងនៅមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌរួមមានពុំមានការឈ្លានពានដោយមិនត្រឹមត្រូវឡើយ ពីព្រោះថា មន្ត្រីយោធាម្នាក់នោះ ប្រាកដជាដឹងមុនថាអ្នកដែលចូលមកក្នុងផ្ទះរបស់ខ្លួនពេលយប់ គឺជាសាហាយដែលប្អូនប្រុសបង្កើតរបស់ខ្លួន ហើយក៏រង់ចាំសម្លាប់តែម្តងទៅ។ ម្យ៉ាងទៀត គឺមិនចាំបាច់ក្នុងការពារខ្លួនទេ មន្ត្រីយោធាម្នាក់នោះ បានបាញ់សម្លាប់យកតែម្តង បន្ទាប់ពីគាត់បានភ្ញាក់ដឹងខ្លួន។បន្ថែមពីនេះ មិនមានភាពសមាមាត្ររវាងមធ្យោបាយដែលបានប្រើដោយសារការតាមទាន់នឹងផិតក្បត់តែកំហឹង បានធ្វើឱ្យបុរសជាមន្ត្រីយោធា បានយកកាំភ្លើងបាញ់បុគ្គលដែលជាប្អូនប្រុសខ្លួនឱ្យរងរបួសធ្ងន់ធ្ងរ។ ក្នុងស្ថានភាពនេះមធ្យោបាយដែលមន្ត្រីយោធា និងភាគី ខ បានប្រើប្រាស់ក្នុងការតបតទៅនឹង អំពើរបស់មន្ត្រីយោធា គឺមិនមានវិសមាមាត្រជាមួយនឹងអំពើឈ្លានពាន កាំភ្លើង និង ដៃ ដូច្នេះអំពើរបស់មន្ត្រីយោធា មិនស្ថិតក្នុងការការពារស្របច្បាប់ទេពោល គឺមន្ត្រីយោធាមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ។

# ជំពូកទី៣
# អានុភាពនៃការការពារស្របច្បាប់

# ជំពូកទី៣

# អានុភាពនៃការការពារស្របច្បាប់

អានុភាពនៃការការពារស្របច្បាប់ គ្រប់បទបញ្ញត្តទាំងឡាយដែលទាក់ទងទៅនឹងការការពារស្របច្បាប់ មានអានុភាពរួចផុតពីទោស ដែលក្នុងនោះអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌផង និងរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីផង។

## ៣.១. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

ការរួចផុតពីការទទួលខុសត្រូវនេះឈរលើមូលដ្ឋាននៃមតិ ៣ ដែលមានតម្លៃជាសាកល និង ជាអចិន្ត្រៃយ៍ផងនោះជាអាទិ៍គឺ៖

- អ្នកដែលប្រព្រឹត្តបទល្មើសពីព្រោះវាគ្មានមធ្យោបាយណាផ្សេងទៀតទេ សម្រាប់ការពារខ្លួនឯង ឬការពារអ្នកដទៃ ហើយវាមិនមែនជាភស្តុតាងនៃអំពើខិលខូច។ ដូច្នេះការអនុវត្តទោសវាជាការអយុត្តិធម៌។ ចំណុចនេះចង់បញ្ជាក់ថា ជនដែលប្រព្រឹត្តបទល្មើសនោះមានតែមធ្យោបាយមួយគត់សម្រាប់ការពារខ្លួនឯង ឬអ្នកដទៃ ហើយមិនមែនជាអំពើខិលខូចនោះបានន័យ ថាដើម្បីការពារខ្លួនឯង ឬ អ្នកដទៃ ជននោះហ៊ានដាច់ចិត្តសម្លាប់ ឬ កាប់ ឬ វាយជនដែលមានចេតនាទុច្ចរិតនោះឱ្យបញ្ឈប់អំពើខិលខូចរបស់ខ្លួន។ ចំណែកឯឃ្លាថាវាមិនមែនជាភស្តុតាងនៃអំពើខិលខូចនោះ បានន័យថាអំពើរបស់អ្នកតបតពុំមែនជាអំពើផ្ទុយនឹងបញ្ញត្តច្បាប់ដូចជាការលួច ឆក់ ប្លន់...។ល។

**ឧទាហរណ៍:** ចោរមួយក្រុមបានវាយបំបែកសោរផ្ទះរបស់ ពូសុខ ដើម្បីចូលប្លន់ទ្រព្យសម្បត្តិរបស់គាត់ ភ្លាមនោះ ពូសុខ ក៏បានយកកាំបិតកាប់ទៅលើចោរនោះ ដើម្បីការពារអាយុជីវិតក្រុមគ្រួសារ និងទ្រព្យសម្បត្តិរបស់គាត់ពីការឈ្លានពានរបស់ក្រុមចោរ ដូចនេះ ពូសុខ ពុំត្រូវបានទទួលទោសព្រហ្មទណ្ឌនោះទេ ។

បន្ទាប់មកតាមវិធានទូទៅ គ្មានជនណាម្នាក់អាចធ្វើជាចៅក្រមសម្រេច សេចក្តីរឿងរបស់ខ្លួនឯងនោះឡើយ ។ ពោលគឺមានតែសង្គមទេ ដែលជាអ្នកទទួលបន្ទុកការពារបុគ្គលទាំងឡាយនៅក្នុងសង្គម។ ប៉ុន្តែនៅពេលដែលមានមនុស្សម្នាក់ត្រូវបានគេវាយប្រហារភស្តុតាងជាក់ស្តែង គឺជាកិច្ចការពាររបស់សង្គមត្រូវបរាជ័យ ដូច្នេះឯកជនត្រូវតែទទួលបាននូវសិទ្ធិការពារខ្លួនឯងដោយផ្ទាល់។ ចំណុចនេះចង់បញ្ជាក់ថា គ្មានជនណាម្នាក់មានសិទ្ធិសម្រេចសេចក្តីដោយខ្លួនឯងបានឡើយ ពោលគឺជាបន្ទុករបស់សង្គមទេដែលជាអ្នកការពារនូវរាល់បុគ្គលទាំងឡាយដែលនៅក្នុងសង្គមនោះ។ ស្ថាប័នតុលាការជាអ្នកដោះស្រាយនូវរាល់បញ្ហាទាំងឡាយដែលពលរដ្ឋក្នុងសង្គមនោះរស់នៅ។ ជាក់ស្តែងនៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា១២៨ថ្មី បានបញ្ញត្តថា អំណាចតុលាការនេះគ្របដណ្តប់គ្រប់រឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។ ប៉ុន្តែ នៅ ពេល

ដែលមានមនុស្សម្នាក់ត្រូវបានគេវាយប្រហារភ្លាមៗនោះសង្គមមិនអាចការពារគេបានទេព្រោះ ថាភស្តុតាងជាក់ស្តែង គឺកិច្ចការពារនៃសង្គមនោះត្រូវបានបរាជ័យ ដូច្នេះឯកជនត្រូវតែទទួលបានមកវិញនូវសិទ្ធិការពារខ្លួនឯងត្រង់ ចំណុចនេះហើយបានជាគេផ្តល់ឱ្យបុគ្គលឯកជន នោះនូវសិទ្ធិការពារខ្លួនឯងដោយផ្ទាល់ពោល គឺការការពារស្រប ច្បាប់។

**ឧទាហរណ៍:** បុរស **ក** បានប្រព្រឹត្តអំពើបង្ករបួសដល់ បុរស **ខ** ពេលនោះកិច្ចការពាររបស់សង្គមសំរាប់ បុរស **ខ** ត្រូវបានបរាជ័យហើយ បុរស **ខ** ក៏ទទួលបាននូវសិទ្ធិសម្រាប់ការពារខ្លួនឯង តែម្តងពោលគឺ បុរស **ខ** មាន សិទ្ធិវាយតបតទៅ បុរស **ក** វិញ។ ក្នុងករណីនេះបុរស **ខ** មិនមានទោសទេ។

- ទីបញ្ចប់គឺ នៅពេលដែលមានមនុស្សត្រូវបានគេវាយប្រហារមានផលប្រយោជន៍ពីរ បានកើតឡើងចំពោះ មុខ គឺផលប្រយោជន៍របស់អ្នកឈ្លានពានគេ និងផលប្រយោជន៍របស់អ្នកដែលរងគ្រោះ។ វាមានការស្របគ្នាទៅ នឹងផលប្រយោជន៍របស់សង្គមផងដែរ គឺផលប្រយោជន៍ របស់ជនរងគ្រោះត្រូវបានគេយកចិត្តទុកដាក់ជាង ផលប្រយោជន៍របស់អ្នកឈ្លានពានគេ។ ត្រង់ចំណុចនេះបានកំណត់នូវតម្លៃជាផលប្រយោជន៍ នៃជនដែលត្រូវ បានគេឈ្លានពានធំជាង ផលប្រយោជន៍នៃអ្នកឈ្លានពានគេ ដូច្នេះអ្នកដែលត្រូវបានគេឈ្លានពានអាចប្រើ សិទ្ធិតបតដោយសមល្មម និងកម្លាំងដែលគេបានឈ្លានពានមកលើខ្លួននោះ។

**ឧទាហរណ៍:** ចោរម្នាក់ដោយចង់បានម៉ូតូដែលចតនៅតាមដងផ្លូវរបស់ជនរងគ្រោះ ក៏បានប្រើកម្លាំងបាយ ក្នុងគោលបំណងប្លន់យកម៉ូតូរបស់ជនរងគ្រោះ ពេលនោះជនរងគ្រោះមកទាន់ដោយសារតែចង់ការពារម៉ូតូរបស់ ខ្លួនគេក៏ប្រើកម្លាំងទប់ទល់ និងអំពើរបស់ចោរប្លន់នោះវិញភ្លាមៗតែម្តង។

### ៣.១.១. សេចក្តីសម្រេចរបស់អយ្យការ

ត្រង់ចំណុចនេះយើងសូមលើកយកនិយមន័យរបស់អយ្យការមកបញ្ជាក់ជាមុនសិន។ ស្ថាប័នអយ្យការ គឺជាតំណាងរបស់អង្គការនីតិប្រតិបត្តិនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ មានតួនាទីជាអ្នកធ្វើបណ្តឹងអាជ្ញា មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញ និងជាគូក្តីដើមជានិច្ចក្នុងរឿងព្រហ្មទណ្ឌ។ អង្គការអយ្យការនេះមានភារកិច្ចស្វែង រកជនល្មើស ប្រមូលភស្តុតាង ចោទប្រកាន់ជនល្មើស ដែកញែកអំពើប្រព្រឹត្តរបស់ជនល្មើសដោយចង្អុល បង្ហាញភស្តុតាងដើម្បីបញ្ជាក់ពីពិរុទ្ធភាពលើជនល្មើស ហើយសុំឱ្យតុលាការធ្វើការផ្តន្ទាទោសលើជនល្មើស រៀបចំបញ្ជូនជនល្មើសទៅតុលាការ កាត់ទោស និងតាមដានការអនុវត្តសាលក្រមរបស់តុលាការ។ អ្នកបម្រើ ការងារនៅស្ថាប័នអយ្យការ នៅតុលាការខេត្ត ក្រុង គេហៅថាព្រះរាជអាជ្ញាដែលអមដោយព្រះរាជអាជ្ញារងមួយរូប ឬ ច្រើនរូប។ ចំណែកឯនៅសាលាឧទ្ធរណ៍ (មានតែនៅភ្នំពេញតែប៉ុណ្ណោះ) តំណាងមហាអយ្យការគេហៅថា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានអគ្គព្រះរាជអាជ្ញាមួយរូប អមដោយអគ្គព្រះរាជអាជ្ញារង និង

ព្រះរាជអាជ្ញាច្រើនរូប។ រីឯមហាអយ្យការអមតុលាការកំពូល គេហៅថាអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដែលមានអគ្គព្រះរាជអាជ្ញាមួយរូប អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាជាច្រើនរូប។

នៅពេលដែលបានវាយតម្លៃលើឧបករណ៍ដែលប្រើប្រាស់ ដើម្បីតបតប្រឆាំង និងអំពើឈ្លានពានហើយ ព្រះរាជអាជ្ញាត្រូវចេញសេចក្តីសន្និដ្ឋានមួយទៅឱ្យចៅក្រមស៊ើបសួរ។ ក្នុងសេចក្តីសន្និដ្ឋាននោះត្រូវបញ្ជាក់ពីពេលវេលា និងគោលបំណងក្នុងការតបតប្រឆាំង និងអំពើឈ្លានពានឱ្យសមល្មមរវាងការតបត និងអំពើវាយប្រហារ សំដៅមកលើខ្លួនវិញ។ បើការតបតប្រឆាំងនិង អំពើឈ្លានពាននោះមានលក្ខណៈលើសលុប និងត្រូវចាត់ចូលក្នុងការការពារហួសព្រំដែនដែលនឹងទទួលទោសព្រហ្មទណ្ឌតាមសេចក្តីបញ្ញត្តច្បាប់។ ក្នុងករណីដែលអយ្យការយល់ឃើញថាអំពើដែលគេប្ដឹងផ្តល់មកនោះមិនចូលក្នុងប្រភេទបទល្មើសព្រហ្មទណ្ឌទេ ឬគ្មានភស្តុតាងណាមួយគួរឱ្យជឿថាពិតជាមានបទល្មើសកើតឡើងមែននោះ ព្រះរាជអាជ្ញានឹងចេញដីកាតម្កល់រឿងទុកឥតចាត់ការដោយសំអាងច្បាប់ និងសំអាងហេតុ។[24]

ដីកាតម្កល់រឿងទុកឥតចាត់ការ គឺជាសេចក្តីសម្រេចរបស់ស្ថាប័នអយ្យការក្នុងការតម្កល់រឿងទុកមួយអន្លើដោយមិនបានធ្វើការចោទប្រកាន់ ឬ បណ្តឹងអាជ្ញាឡើយ។ ដីកាតម្កល់រឿងទុកឥតចាត់ការ អាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ខែ គិតចាប់ពីថ្ងៃទទួលដំណឹងពីដីកានេះដោយអ្នកប្តឹងដាក់ពាក្យនៅអយ្យការពាក់ព័ន្ធ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថាការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាចេញអធិបញ្ជាឱ្យ ព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់។ ទោះបីជាយ៉ាងណាក្តី សេចក្តីសម្រេចនេះពុំមាន អាជ្ញាអស់ជំនុំទេ ដោយព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញនៅពេលដែលបណ្តឹងអាជ្ញាមិនទាន់រលត់។

### ៣.១.២. សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកការពិត ហើយតួនាទីយ៉ាងសំខាន់របស់ចៅក្រមស៊ើបសួរ គឺការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន។

ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរ តែក្នុងករណីដែលមានដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរពីអយ្យការប៉ុណ្ណោះ។ ទោះបីជាចៅក្រមស៊ើបសួរទទួលពាក្យប្តឹងដោយមានការតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវតែទទួលបាននូវដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរពីអយ្យការជាមុនសិន ទើបអាចធ្វើការសាកសួរបាន។ ម្យ៉ាងវិញទៀត ដោយយោងទៅ លើសមត្ថកិច្ចចងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ពុំអាចស៊ើបសួរទៅលើអង្គហេតុដែលពុំមាននៅក្នុងដីកាសន្និដ្ឋាន

[24] មាត្រា៤១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០៣០, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

នេះឡើយ មានន័យថាចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ ពោលចៅក្រមស៊ើបសួរមិនមានកាតព្វកិច្ច សម្រេចតាមការវាយតម្លៃកំណត់បទល្មើស ដោយព្រះរាជអាជ្ញាកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ គឺចៅក្រមស៊ើបសួរមានសេរីភាពពេញលេញ ក្នុងការកំណត់បទល្មើសផ្សេងពីការកំណត់បទល្មើសដោយព្រះរាជអាជ្ញា កុំឱ្យតែការកំណត់បទល្មើសនោះទាក់ទងនឹងអង្គហេតុថ្មី ដែលពុំមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ក្រោយពីបានស៊ើបសួរចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនព័ត៌មានពីការបិទការស៊ើបសួរជូនទៅកាន់ព្រះរាជអាជ្ញា ដោយចេញជា លិខិតជូនព័ត៌មាន ឬ ជូនដំណឹង។

ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានជាស្ថាពរត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។ ចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយដែលមានសំអាងហេតុ និងជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។ ដីកាដំណោះស្រាយអាចជា:

- ដីកាសម្រេចបញ្ជូន សំណុំរឿងទៅជំនុំជម្រះ ជនត្រូវចោទបញ្ជូនទៅតុលាការជំនុំជម្រះ បទឧក្រិដ្ឋ ឬ មជ្ឈិម។ ដោយចៅក្រមស៊ើបសួរត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះ បទល្មើសតាមច្បាប់។
- ដីកាលើកលែងចោទប្រកាន់ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ ក្នុងករណីអំពើប្រព្រឹត្ត មិនមែន ជាបទឧក្រិដ្ឋ ឬ មជ្ឈិម ឬ លហុជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

ដីកាដំណោះស្រាយ គឺជាដីកាបិទការស៊ើបសួរ ដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ក្នុងករណីដែលជាដីកាលើកលែងចោទប្រកាន់ដីកាដំណោះស្រាយសម្រេចពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុចាប់យក។

### ៣.១.៣. សេចក្តីសម្រេចរបស់ចៅក្រមជំនុំជម្រះ

ការជំនុំជម្រះ គឺជាការវិនិច្ឆ័យទៅលើជនជាប់ពិរុទ្ធ ដើម្បីធ្វើការកំណត់ទោស ឬ ត្រូវដោះលែងឱ្យមានសេរីភាពវិញ ប្រសិនបើជនជាប់ពិរុទ្ធនោះបានប្រព្រឹត្តបទល្មើសប្រាកដមែន ហើយបង្កមហន្តរាយដល់អ្នកដទៃបណ្តាលឱ្យទទួលរងការខូចខាត ដើម្បីឱ្យជននោះស្គាល់ និងភ្ញាក់រលឹកដឹងអំពីកំហុសរបស់ខ្លួនរាងចាលលែងប្រព្រឹត្តបទល្មើសទៀត ជាការស្វែងរកភាពសុខដុមជូនប្រជាពលរដ្ឋ និងរៀបចំរបៀបរៀបរយសណ្តាប់ធ្នាប់សង្គម និងសន្តិសុខសាធារណៈ។

នៅក្នុងដំណាក់កាលសួរដេញដោល គឺជាការស៊ើបអង្កេតមួយរបស់ចៅក្រមជំនុំជម្រះនៅក្នុង ពេលជំនុំជម្រះ ដូចជាការសួរតទល់រវាងជនជាប់ចោទ សាក្សី និងជនរងគ្រោះ ដើម្បីផ្ទៀងផ្ទាត់ភស្តុតាងទាំងឡាយ និងពិនិត្យមើលលើធាតុផ្សំនៃបទល្មើស តើជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសតាមការចោទប្រកាន់របស់ព្រះរាជអាជ្ញា ក៏ដូចជាដីកាបញ្ជូនរឿងមក ជំនុំជម្រះរបស់ចៅក្រមស៊ើបសួរដែរ ឬ ទេ។ ដូចនេះនៅក្នុងដំណាក់កាលសួរដេញដោលពេលសវនាការ គឺជាដំណាក់កាលមួយមិនអាចខ្វះបាននៅក្នុងនីតិវិធីជំនុំជម្រះរឿងក្តី ហើយគ្មានការជំនុំជម្រះរឿងក្តីណាដែលមិនឆ្លងកាត់ដំណាក់កាលសួរដេញដោលនេះឡើយ។ ក្រោយពេលសួរដេញដោលចប់ គឺត្រូវមានការសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ហើយការសន្និដ្ឋានរបស់មេធាវី គឺត្រូវចេញសាលក្រមដែលសាលក្រមនោះត្រូវប្រកាសជាសាធារណៈ ថាមានពិរុទ្ធភាព គ្មានពិរុទ្ធភាព ទទួលទណ្ឌកម្ម និងសំណងរដ្ឋប្បវេណីកម្រិតណាមួយ។

បន្ទាប់ពីស្តាប់ការសន្និដ្ឋានរបស់ព្រះរាជអាជ្ញា និងមេធាវីចប់សព្វគ្រប់ហើយចៅក្រមជំនុំជម្រះនឹងធ្វើការពិចារណាទៅលើអង្គហេតុ និងអង្គច្បាប់នៃហេតុការណ៍ទាំងឡាយដែលបានកើតមាននិងបានប្រមូលនៅពេលសវនាការក្នុងដំណាក់កាលសួរដេញដោល ដើម្បីសម្រេចក្នុងការប្រកាសសាលក្រម។ ការប្រកាសសាលក្រមត្រូវធ្វើនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬ នៅពេលសវនាការលើកក្រោយ ដែលកាលបរិច្ឆេទត្រូវកំណត់ដោយប្រធានសវនាការ។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈដោយប្រធានសវនការអានដោយ សម្លេងខ្លាំងៗនៃផ្នែកសេចក្តីសម្រេចរបស់សាលក្រម។[25]

ក្នុងករណីដែលចៅក្រមជំនុំជម្រះយល់ឃើញថា សំណុំរឿងដែលជំនុំជម្រះនេះមិនចូលជា បទល្មើសព្រហ្មទណ្ឌណាមួយ បានន័យថាគ្មានភស្តុតាងគ្រប់គ្រាន់ ឬអំពើដែលបានប្រព្រឹត្តនោះគ្រាន់ជាការការពារខ្លួន ដូចនេះចៅក្រមជំនុំជម្រះសម្រេចឱ្យ ជនជាប់ចោទរួចផុតពីបទចោទប្រកាន់។ នៅពេលប្រកាសសាលក្រម ចៅក្រម ត្រូវតែប្រកាសអំពីមូលហេតុទាំងឡាយដែលនាំមកនូវការ សម្រេចនៅក្នុងសាលក្រម ទន្ទឹមនឹងនោះដែរត្រូវប្រកាសអំពីសេចក្តីសម្រេចនៅក្នុងសាលក្រមរបស់ខ្លួន ដើម្បីឱ្យគូភាគីអនុវត្តតាមហើយត្រូវបើកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចនេះ ទៅតាមកំណត់ច្បាប់រួចហើយប្រកាសបិទសវនាការតែម្តង។

### ៣.២. ការរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី

អំពើការពារជាធម្មានុរូប ឬ ការការពារស្របច្បាប់ សំដៅទៅលើអំពើរំលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលា នៃអំពើរំលោភបំពាននោះ ស្ថិតជិតគ្នា និងមានតុល្យភាពរវាងវិធីការពារ និងកម្រិតនៃ

[25]មាត្រា៣៥៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០៣០, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

អំពើបំពាននោះ។[26] អំពើដែលកើតចេញពីការការពារស្របច្បាប់ គឺមិនត្រឹមតែពុំចាំបាច់ទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះទេតែក៏អាចរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីថែមទៀតផង។ការរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីមានដូចជា ការរួចផុតពីការទទួលខុសត្រូវលើវត្ថុ និងសត្វ និងការរួចផុតពីការទទួលខុសត្រូវលើសកម្មភាព។

### ៣.២.១. ការរួចផុតពីការទទួលខុសត្រូវលើវត្ថុ និងសត្វ

គ្រប់ព្យសនកម្មទាំងអស់ដែលបានកើតឡើងដោយសារវត្ថុ មិនមែនសុទ្ធតែត្រូវទទួលខុសត្រូវនោះទេ។ ជាគោលការណ៍ វត្ថុរួមមាន ចលនវត្ថុ និងអចលនវត្ថុ។ ក្នុងករណីដែលមានការខូចខាតដោយសារវត្ថុហើយការខូចខាតនោះបណ្តាលមកពីប្រធានសក្តិ ឬ ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់គ្មានវិការៈ ហើយការខូចខាតបានកើតឡើងដោយសារអំពើរបស់ជនរងគ្រោះ ឬ តតិយជន ម្ចាស់វត្ថុ ឬ អ្នកគ្រប់គ្រងវត្ថុនោះអាចរួចផុតពីការទទួលខុសត្រូវបាន។[27]

**ឧទាហរណ៍:** បុរស **ក** បានខ្ចីម៉ូតូរបស់ បុរស **ខ** ដើម្បីជូនប្រពន្ធទៅសម្រាលនៅមន្ទីរពេទ្យ។ បន្ទាប់ពីជូនប្រពន្ធទៅមន្ទីរពេទ្យ បុរស **ក** ក៏បានជិះត្រលប់មកវិញដើម្បីសងម៉ូតូទៅ បុរស **ខ** វិញ ប៉ុន្តែនៅតាមផ្លូវ ត្រលប់មកវិញ បុរស **ក** បានជិះបុកម៉ូតូរបស់ បុរស **គ** បណ្តាលឱ្យមានការខូចខាត។ ក្នុងករណីនេះ ការសងសំណងទៅលើ បុរស **គ** ពុំមែនជាបន្ទុករបស់ បុរស **ខ** ឡើយ ពោលគឺ បុរស **ក** ត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនបើទោះបីជាម៉ូតូនោះជារបស់ បុរស **ខ** ក៏ដោយ។

### ៣.២.២. ការរួចផុតពីការទទួលខុសត្រូវលើសកម្មភាព

ចំពោះការខូចខាតដែលកើតមានឡើង ដោយសារអំពើនៃការការពារដោយស្របច្បាប់ និងអំពើដែលត្រូវសង្គមទទួលស្គាល់ថាសមហេតុផល អ្នកដែលបានប្រព្រឹត្តអំពើការពារពុំត្រូវទទួលខុសត្រូវឡើយ។[28]

ជាទូទៅ រាល់សកម្មភាពទាំងឡាយណាដែលនាំឱ្យមានការខូចខាតដល់អាយុជីវិត ទ្រព្យសម្បត្តិរបស់អ្នកដទៃ គឺត្រូវបានច្បាប់ចាត់ទុកថាជាបទល្មើស និងត្រូវមានការទទួលខុសត្រូវពីសំណាក់អ្នកប្រព្រឹត្ត។ ទោះជាយ៉ាងណាក៏ដោយ ក៏មាននូវសកម្មភាពមួយចំនួនដែលអាចរួចផុតពីការទទួលខុសត្រូវដែរ។ អំពើទាំងនោះរួមមានសកម្មភាពការពារខ្លួន និងសកម្មភាពការពារអ្នកដទៃ។

---

[26] មាត្រា៧៥៥ កថាខណ្ឌទី១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០៣០, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧។

[27] មាត្រា៧៥២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០៣០, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[28] មាត្រា៧៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០៣០, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- **សកម្មភាពការពារខ្លួន**

សកម្មភាពការពារខ្លួន គឺជាសកម្មភាពទាំងឡាយណាដែលត្រូវបានស្តែងឡើងក្នុងន័យ ការពារខ្លួន ក៏ដូចជាទ្រព្យសម្បត្តិរបស់ខ្លួនឯង។

**ឧទាហរណ៍:** ចោរម្នាក់បានព្យាយាមកាច់សោរម៉ូតូរបស់លោក **ក** ដែលចតទុកនៅមុខផ្ទះ ពេលនោះលោក **ក** បានឃើញនូវសកម្មភាពរបស់ចោរ ហើយគាត់ក៏បានយកដំបងទៅវាយចោរ នោះបណ្ដាលឱ្យរងរបួស។ លោក **ក** ពុំចាំបាច់ទទួលខុសត្រូវសងនូវសំណងទៅដល់ចោរនោះទេ ពីព្រោះថាអំពើរបស់លោក **ក** ធ្វើឡើងក្នុងគោលបំណងដើម្បីការពារទ្រព្យសម្បត្តិរបស់គាត់តែប៉ុណ្ណោះ។

- **សកម្មភាពការពារអ្នកដទៃ**

សកម្មភាពការពារអ្នកដទៃ គឺជាសកម្មភាពទាំងឡាយណាដែលប្រព្រឹត្តឡើងដើម្បីការពារ អាយុជីវិត ឬទ្រព្យសម្បត្តិរបស់អ្នកដទៃ។

**ឧទាហរណ៍:** ជនម្នាក់ ដើម្បីជួយទារកដែលមានអាយុមួយខួប ដែលបានភ្លេចក្នុងឡាន ដោយគាត់ក៏បាន ចូលទៅរំដោះដោយបានបំបែកកញ្ចក់ យកទារកចេញពីរថយន្ត និងបានបញ្ជូនទារកអ្នកជិតខាងរបស់គាត់ទៅកាន់មន្ទីរពេទ្យ។ អំពើដែលជននោះ បានធ្វើឱ្យខូតខាតកញ្ចក់ទ្វាររថយន្ត របស់អ្នកជិតខាងគាត់ គឺជាអំពើល្មើសដែលច្បាប់ទទួលស្គាល់ ពោលគឺជា អំពើការពារអ្នកដទៃ ដែលជាការការពារស្របច្បាប់ ដូច្នេះគាត់ពុំចាំបាច់សងសំណងការខូចខាតទៅដល់អ្នកជិតខាងរបស់គាត់នោះ។

# សេចក្តីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើ ប្រធានបទស្តីពីការការពារស្របច្បាប់រួចមកបានបង្ហាញអោយឃើញថាការការពារស្របច្បាប់ គឺជាការតបតដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមិនត្រឹមត្រូវដែលការតបតនោះ មិនត្រូវបានចាត់ទុកថាជាបទល្មើស។ ហើយបណ្តាប្រទេសជាច្រើននៅលើពិភពលោកតែងតែទទួលស្គាល់ថាមនុស្សមានសិទ្ធិការពាររាល់ទ្រព្យសម្បិត្ត អាយុជីវិត ក្រុមគ្រួសាររបស់ពួកគេ ដើម្បីតទល់ជនដ៏ទៃគំរាមកំហែង រំលោភបំពានធ្ងន់ធ្ងរណាមួយពីសំណាក់មនុស្សដ៏ទៃក្តី ពីសំណាក់កម្លាំងនៃធម្មជាតិ ឬ ពីកម្លាំងខាងក្រៅណាមួយក្តី។

ប្រព័ន្ធច្បាប់ជាច្រើនបានអនុញ្ញាតអោយមានការប្រើប្រាស់កម្លាំងដើម្បីការពារខ្លួនការការពារជនដ៏ទៃ ឬទ្រព្យសម្បិត្តប្រព័ន្ធច្បាប់ជាច្រើនបានអនុញ្ញាតឱ្យមានការប្រើប្រាស់កម្លាំង ដើម្បីការពារខ្លួនគេ ការពារជនដទៃ ឬទ្រព្យសម្បត្តិ ដែលអំពើតទល់បែបនេះហៅថា ការការពារខ្លួនស្របច្បាប់ ហើយថ្វីត្បិតតែ អំពើទាំងនេះត្រូវបានព្រះរាជអាជ្ញាបង្ហាញឱ្យឃើញនូវគ្រប់ធាតុផ្សំនៃបទល្មើស ដែលត្រូវបានចោទប្រកាន់ក៏ដោយតែអំពើរបស់ជនត្រូវចោទនេះត្រូវបានច្បាប់អនុញ្ញាត និងទទួលស្គាល់ថាជាអំពើស្របច្បាប់ ពោលគឺជាអំពើដែលមានផលប្រយោជន៍ដល់សង្គមដែលមានផលប្រយោជន៍ដល់ ប្រជាពលរដ្ឋហើយជាទូទៅបណ្តាផលប្រយោជន៍ស្របច្បាប់ទាំងនេះត្រូវបានច្បាប់ការពារដូចៗគ្នា។ ដូច្នេះរាល់ការការពារតទល់ទាំងនេះតែងតែមានការបង្កអន្តរាយដល់អ្នករំលោភបំពានលើផលប្រយោជន៍ដែលច្បាប់ការពារនោះវិញ។ ជាដរាបដោយគ្រាន់តែរាល់ទង្វើទាំងនោះត្រូវឆ្លើយតបសមស្របតាមលក្ខខណ្ឌការការពារស្របច្បាប់ ដែលជាប្រតិកម្មតបមួយដែលច្បាប់អនុញ្ញាតឱ្យជនរងគ្រោះនៃអំពើឈ្លានពានមិនត្រឹមត្រូវ (អនីត្យានុកូល) ធ្វើការតបតដើម្បីការពារអាយុជីវិត និងទ្រព្យសម្បត្តិ។

ក្នុងនោះផងដែរច្បាប់អនុញ្ញាតឱ្យមានការការពារបូរណភាពរូបរាងកាយ និងទ្រព្យសម្បត្តិពីការទទួលរងគ្រោះផ្សេងៗ ដែលកើតចេញពីការឈ្លានពាន (អំពើឈ្លានពាន) ណាមួយ។ ការអនុញ្ញាតនេះចាំបាច់ណាស់ទោះបីជាប្រតិកម្មនេះស្តែងចេញតាមរូបភាពបែបហិង្សាក៏ដោយ ក៏ត្រូវតែស្ថិតនៅក្នុងលក្ខខណ្ឌដែលច្បាប់ព្រហ្មទណ្ឌកំណត់តែប៉ុណ្ណោះ។ បទល្មើសត្រូវចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួនការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។ ហើយបទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់និងទម្ងន់នៃការឈ្លានពាន។

ដោយឡែកក៏ដូចជាប្រភេទនៃយុត្តិកម្មដទៃទៀតដែរ ជនជាប់ចោទដែលលើកសំអាងពីការពារស្របច្បាប់ត្រូវតែរកភស្តុតាងមកបញ្ជាក់ពីអត្ថិភាពនៃការកាពារ។ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌបានសន្មតនូវករណីពីរយ៉ាង

ពោលគឺជនចាប់ចោទ មិនចាំបាច់ត្រូវស្វែងរកភស្តុតាងពីលក្ខខណ្ឌទាំងឡាយ ដែលក្រមព្រហ្មទណ្ឌបានចែងពីការការពារស្របច្បាប់បានន័យថា ក្រមព្រហ្មទណ្ឌបានសន្មតថាជននោះបានទទួលបានការការពារស្របច្បាប់តែម្តង។ ហើយអានុភាពនៃការការពារស្របច្បាប់ គ្រប់បទបញ្ញត្តទាំងឡាយដែលទាក់ទងទៅនឹងការការពារស្របច្បាប់ មានអានុភាពរួចផុតពីទោស ដែលក្នុងនោះអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌផង និងរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីផង។

ក្នុងការអនុវត្តជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងបច្ចុប្បន្ន ការការពារស្របច្បាប់ត្រូវបានអ្នកច្បាប់ និងស្ថាប័នអនុវត្តច្បាប់ ជាពិសេសគឺ ស្ថាប័នតុលាការបានទទួលស្គាល់ថាជាអំពើស្របច្បាប់ធម្មជាតិស្របច្បាប់សីលធម៌ជាអំពើបញ្ចៀសបាននូវចរិតគ្រោះថ្នាក់ដល់សង្គម និងបញ្ចៀសបាននូវចរិតគ្រោះថ្នាក់នៃអំពើហើយជន ដែលបានប្រព្រឹត្តនូវអំពើនោះ ត្រូវបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ និងការទទួលខុសត្រូវរដ្ឋប្បវេណី ពោលគឺទោះបីព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ក្តី ក៏នៅពេលសវនាការចៅក្រមជំនុំជម្រះតែងតែសម្រេចឱ្យជននោះបានរួចខ្លួនដោយសំអាងលើទ្រឹស្តីនីតិព្រហ្មទណ្ឌ និងគោលការណ៍ ច្បាប់ដែលចែងពីការការពារខ្លួនស្របច្បាប់។ រាល់អំពើទាំងឡាយក្នុងការការពារស្របច្បាប់ គឺ សុទ្ធតែជាទង្វើដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស និងសិទ្ធិរស់រានមានជីវិតរបស់មនុស្ស មានន័យថាគឺជាអំពើដែលស្តែងចេញអំពីសិទ្ធិជានីត្យានុកូលរបស់ភាគីជនរងគ្រោះ ដែលមិនអាចបញ្ចៀសនូវគ្រោះថ្នាក់ ឬ អំពើជាអនីត្យានុកូលពីសំណាក់ជនរំលោភបំពាននោះបាន ក៏បានប្រើសិទ្ធិស្របច្បាប់នេះប្រឆាំងតទល់វិញ ដើម្បីការពារអាយុជីវិតរបស់ខ្លួន អាយុជីវិតអ្នកដទៃទ្រព្យសម្បត្តិឯកជនទ្រព្យសម្បត្តិសាធារណៈ។ ល។

សរុបមកការការពារស្របច្បាប់ ជាការលើកទឹកចិត្តបំផុសបំផុលដល់ជនគ្រប់ស្រទាប់ទាំងអស់ឱ្យមានស្មារតីចេះជួយសម្រាលទុកធុះគ្នា ដើម្បីប្រឆាំងទៅនឹងអំពើរំលោភបំពានដែលកើតមានឡើងចំពោះសង្គមដែលអាចប៉ះពាល់ និងនាំឱ្យមានការខូចខាតមិនត្រឹមតែទ្រព្យសម្បត្តិឯកជន មិនត្រឹមតែប៉ុណ្ណោះអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈថែមទៀតផង។ ចំពោះអំពើដែលច្បាប់អនុញ្ញាត វាអាចធ្វើឱ្យមនុស្សមានចិត្តក្លាហានក្នុងការជួយជនរងគ្រោះ ពីជនណាម្នាក់ប្រព្រឹត្តបទល្មើសមិនស្របច្បាប់ណាមួយ ទៅលើអ្នកដទៃទៀតដោយមិនការរុញរា។ ហើយលើសពីនេះទៅទៀតពួកគេអាចបង្កើតបាននូវទំនាក់ទំនងជិតស្និទ្ធរវាងគ្នា និងគ្នាបានទៀតផងដែលផ្សាភ្ជាប់ទៅនឹងផលប្រយោជន៍សង្គម ជួយស្តារ និងស្ថាបនា ក៏ដូចជាការទប់ស្កាត់ការកើតកើតអំពើល្មើសច្បាប់ផ្សេងៗ ក៏ដូចជាការថែរក្សាបាននូវសន្តិសុខ ភាពសុខដុមរមនា សុខសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ដើម្បីឱ្យសង្គមជាតិឈានទៅរកការអភិវឌ្ឍន៍ជានិរន្ត ហើយសិទ្ធិទាំងនេះគឺជា សិទ្ធិការពារស្របច្បាប់ទៅលើមូលដ្ឋានសម្រាប់មនុស្សជាតិគ្រប់រូបដែលរស់នៅក្នុងសង្គមមួយនេះ។

# អនុសាសន៍

មនុស្សគ្រប់រូបដែលរស់នៅក្នុងសង្គមចាំបាច់ត្រូវយល់ដឹងអំពីច្បាប់ ហើយជាពិសេសគឺច្បាប់ព្រហ្មទណ្ឌ តែម្តងថាតើអំពើបែបណាខ្លះដែលចាត់ទុកថាជាការការពារស្របទៅតាមច្បាប់ ដើម្បីបម្រើប្រយោជន៍ប្រជាពលរដ្ឋ នៅក្នុងសង្គម ហើយជនល្មើសក្នុងរឿងព្រហ្មទណ្ឌតែងតែប្រព្រឹត្ត អំពើដោយមិនស្របច្បាប់ព្រមទាំងការទទួល ខុសត្រូវនូវរាល់អំពើល្មើស ដែលខ្លួនបានប្រព្រឹត្តផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌផងដែរ។ នៅក្នុងទិដ្ឋភាពជាក់ស្តែង យើងឃើញថាក្នុងសង្គមមានបញ្ហារាប់រយជំពូកដែល កើតឡើងមិនមានការយោគយល់អធ្យាស្រ័យគ្នាទៅ វិញទៅមក រហូតកើតជាទំនាស់រហូតដល់ការបាត់បង់ជីវិត ហើយអំពើតទល់ ឬ ការការពាររបស់មនុស្សដែល ពិនិត្យលើរូបភាពខាងក្រៅមានរូបរាងដែលជាបទល្មើសដែលច្បាប់ព្រហ្មទណ្ឌ បានបញ្ញាតក៏ប៉ុន្តែអំពើនោះបាន បំពេញតាមលក្ខខណ្ឌដែលច្បាប់ព្រហ្មទណ្ឌទទួលស្គាល់។ ហេតុនេះត្រូវបានច្បាប់ចាត់ទុកថាជាអំពើមាន ប្រយោជន៍ដល់សង្គមជាអំពើស្របច្បាប់ ហើយជនដែលបានប្រព្រឹត្តអំពើនោះត្រូវរួចផុតពីការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌ។

ក្នុងនោះផងដែរក៏មានបញ្ហាកង្វះខាតធនធានទាក់ទងនឹងសម្ថភាពខាងផ្លូវច្បាប់ដូចបច្ចេកទេស ឧបករណ៍ស្រាវការធ្វើកោសល្យវិច្ច័យ ការយកចិត្តទុកដាក់ក្នុងពេលបំពេញតួនាទីនៅមិនទាន់មានភាពប្រសើរ នៅឡើយមានចំណុចអសកម្មផ្សេងៗពាក់ព័ន្ធនឹងបច្ចេកទេសក្នុងការសន្និដ្ឋាន នៃគោលការណ៍អនុវត្តច្បាប់ផ្សេងៗ មិនទាន់មានការអនុវត្តពេញលេញក៏ដូចការអនុវត្តច្បាប់នៅមានកម្រិត ដោយការផ្សព្វផ្សាយច្បាប់មាន ទាន់ទូលំទូលាយ។ ការបកស្រាយអត្ថបទច្បាប់នៅមិនទាន់ភាពពេញលេញនៅឡើយដែលជាហេតុធ្វើអោយ មានចន្លោះប្រហោងរាំងស្ទះដំណើរក្នុងការបំពេញការងារ។

ដើម្បីជាចូលរួមចំណែកធ្វើអោយកាន់តែប្រសើឡើង ក្នុងវិស័យយុត្តិធម៌ក្នុងព្រះរាជាណាចក្រកម្ពុជា អោយកាន់តែរីកលូតលាស់ទៅនឹងវិវត្តន៍ទៅកាន់ភាពរីកចំរើនបម្រើរាស្ត្រទាំងអោយភាពតម្លាភាព នៃយុត្តិធម៌ ស្របតាមបទដ្ឋានគិតយុត្តិផ្សេងៗដែលបានកំណត់ជាពិសេស សិទ្ធិក្នុងការការពារស្របច្បាប់ដែលជាចំណុច មួយសំខាន់ក្នុងការរស់នៅក៏ស្របទៅតាមការកំណត់របស់ច្បាប់ជាតិ លើសពីនេះថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ មេត្តាចាត់វិធានការបន្ថែមដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់បន្តផ្សព្វផ្សាយ ក្រមព្រហ្មទណ្ឌនេះ ដល់ប្រជាពលរដ្ឋឲ្យ បានដឹងកាន់តែច្បាស់ពីក្រមមួយនេះ ជាពិសេសស្ថាប័នតុលាការមេត្តាស៊ើបសួរ និងរកភស្តុតាងឲ្យបាន ច្បាស់លាស់ជាមុនសិននឹងធ្វើការជំនុំជម្រះ ក៏ដូចជាការផ្តល់យុត្តិធម៌ដល់មហាជន។ ហើយអាជ្ញាធរសាធារណៈ មេត្តាពិនិត្យអំពីស្ថានភាពនៃបទល្មើស និងស្រាវជ្រាវឲ្យបានច្បាស់សិនមុននឹងធ្វើកំណត់ហេតុដាក់

ជូនទៅព្រះរាជអាជ្ញា។ ដើម្បីពង្រឹងនឹងបង្ហាញឲ្យឃើញពីការអនុវត្តន៍យ៉ាងមុតមាំទៅតាមដំណើរឆ្ពោះទៅកាន់នីតិរដ្ឋរបស់ប្រទេសកម្ពុជា។

បន្ថែមពីនេះរដ្ឋបាលថ្នាក់ក្រោមជាតិមេត្តាជួយចាត់វិធានការ ឬ ជួយសម្រួលដល់ អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការផ្សព្វផ្សាយច្បាប់ និងរដ្ឋាភិបាល ក៏ដូចជាក្រសួងសាម៉ីត្រូវសហការគ្រឹះស្ថានឧត្តមសិក្សា និងគ្រប់សាកលវិទ្យាល័យទាំងអស់គួរតែបញ្ចូល កម្មវិធីសិក្សាអំពីមុខវិជ្ជាច្បាប់ជាពិសេសពី ក្រមព្រហ្មទណ្ឌនេះដល់សិស្ស និស្សិតដែលមកសិក្សា នៅសាលារបស់ខ្លួន ត្រូវលើកទឹកចិត្តអ្នកដែលមានជំនាញខាងផ្លូវច្បាប់ ដូចជាលោកបណ្ឌិត លោក-លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកប្រកបវិជ្ជាជីវៈច្បាប់ដែលសរសេរសៀវភៅច្បាប់ដែលមានការបកស្រាយក្បោះក្បាយ ងាយយល់ ងាយចាប់បាន ដើម្បីឲ្យអ្នកដែលមិនចេះច្បាប់ ឬ ចេះត្រឹមតែអានអក្សរ ក៏ដូចសិស្សានុសិស្ស អ្នកស្រាវជ្រាវ អាចយល់បានកាន់តែច្បាស់អំពីផ្លូវច្បាប់។

ជាពិសេស ស្ថានីយ៍ទូរទស្សន៍ ស្ថានីយ៍វិទ្យុ ប្រព័ន្ធអ៊ីនធើណែត បើកឲ្យមាននូវកម្មវិធីប្រឹក្សាយោបល់ និងបកស្រាយផ្នែកជំនាញច្បាប់ ក្នុងគោលបំណងផ្សព្វផ្សាយអំពីវិស័យច្បាប់នៅកម្ពុជាអោយបានទូលំលាយ ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាផ្នែកច្បាប់ ក៏ដូចជាអ្នកដែលមានបញ្ហាក្នុងវិស័យច្បាប់នេះផងដែរ ព្រមទាំងប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។ មេត្តាព្យាយាមសិក្សាស្វែងយល់អំពីច្បាប់ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ និងត្រូវតែទទួលយក និងជួយគ្នាអនុវត្តទាំងអស់គ្នា ដើម្បីជៀសវាងកុំអោយធ្លាក់លង់ទៅនឹងការប្រព្រឹត្តបទល្មើសក្លាយជាជនល្មើស ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីតុលាការ និងបណ្តាលអោយខូចប្រយោជន៍ និងពេលវេលាក៏ដូចជាក្រុមគ្រួសារ និងសង្គមជាតិទាំងមូល ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតដ្ឋានគតិយុត្ត

១.រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២.សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៥

៣.កតិការសញ្ញាអន្តជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦

៤.ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៥.ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០៣០, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៦.ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

## វចនានុក្រម និងសទ្ទានុក្រម

១.វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ដែលចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

២.មូលនិធីអាស៊ី វចនានុក្រមច្បាប់អង់គ្លេស ១៩៩៧

## សៀវភៅ

១.រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត នីតិព្រហ្មទណ្ឌទូទៅ ២០១២

២.ហ៊ី សោភា នីតិព្រហ្មទណ្ឌ

៣.រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត នីតិវិធីព្រហ្មទណ្ឌទូទៅ ២០២២

៤.សេង ស៊ីវត្ថា នីតិព្រហ្មទណ្ឌទូទៅ ១៩៩៦

## សារព័ត៌មាន

១.សារព័ត៌មាន ខេ ប៊ី អិន ចេញផ្សាយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២១

២.សារព័ត៌មានសន្តិសុខសង្គម CTV8 ចេញផ្សាយថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧

៣.សារព័ត៌មាន freshnewsasia ចុះផ្សាយនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធ ១** | ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ |
| **ឧបសម្ព័ន្ធ ២** | ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០៣០ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ |
| **ឧបសម្ព័ន្ធ ៣** | ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ |
| **ឧបសម្ព័ន្ធ ៤** | សារព័ត៌មាន ខេ ប៊ី អិន ចេញផ្សាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២១ |
| **ឧបសម្ព័ន្ធ ៥** | សារព័ត៌មានសន្តិសុខសង្គម CTV8 ចេញផ្សាយ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ |
| **ឧបសម្ព័ន្ធ ៦** | សារព័ត៌មាន freshnewsasia ចុះផ្សាយនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ |

**ឧបសម្ព័ន្ធ ១**

# ក្រមព្រហ្មទណ្ឌ

នាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល នៃក្រសួងយុត្តិធម៌
លេខទូរស័ព្ទទំនាក់ទំនង ៖ ០១២ ៩២១ ១១៤, ០២៣ ២១៥ ៦៥៣

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២
## មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

## មាត្រា ៣៣.- ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

## មាត្រា ៣៤.- សច្ចធារណីនៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណីនៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណីនេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្ដិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

ឧបសម្ព័ន្ធ ២

ក្រសួងយុត្តិធម៌

Ministry of Justice

# ក្រមនីតិវិធីព្រហ្មទណ្ឌ

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៧.** – អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ ប៉ុន្តែ កាលណាអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ។

ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលក្រមនេះបានទទួលស្គាល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ ។

ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន ។

**មាត្រា ៣៨.** – អំណាចរបស់ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស ។

**មាត្រា ៣៩.** – សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ :

-ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តិបទល្មើស

-ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស

-ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស ។

## ផ្នែកទី ២
## ការអនុវត្តបណ្តឹងអាជ្ញា

**មាត្រា ៤០.** – ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើស

ព្រហ្មទណ្ឌ ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ។

ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៤១.-** ការតម្កល់រឿងទុកឥតចាត់ការ

កាលណាបណ្តឹងណាមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីដែលមានចែងក្នុងមាត្រា ៥០ (បញ្ជីនៃពាក្យប្តឹង) នៃក្រមនេះ ។

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ ។ ការតម្កល់ទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ ។

ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ ។

ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។

ការតវ៉ានេះត្រូវធ្វើនៅក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ ។ បន្ទាប់មក សំណុំរឿងត្រូវបានបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការអមសាលាដំបូង ។

ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់ ។ អគ្គព្រះរាជអាជ្ញាធ្វើអធិបញ្ញា តាមការណែនាំជាលាយលក្ខណ៍អក្សរ ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ទុកជាបានការ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា ។

**មាត្រា ៤២.-** កាតព្វកិច្ចធ្វើបណ្តឹងបរិហារចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

អាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ខ្លួន បានដឹងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬដល់មន្ត្រីនគរបាលយុត្តិធម៌

ដោយត្រូវបញ្ជូននូវព័ត៌មាន កំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះ ភ្ជាប់ជាមួយផង ។

មិនអាចមានការលើកលែងដទៃណា ក្រៅពីការលើកលែងស្តីអំពីអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ក្នុងករណីដែលច្បាប់បានចែងយ៉ាងជាក់លាក់នោះទេ ។

**មាត្រា ៤៣.** – ការចោទប្រកាន់

ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម :

-ការបើកធ្វើការស៊ើបសួរ

-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ

-តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

**មាត្រា ៤៤.** – ការបើកការស៊ើបសួរ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។

ការស៊ើបសួរត្រូវបានបើក តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរ អាចបើកប្រឆាំងលើ បុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន :

-សេចក្តីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះ ត្រូវទុកជាមោឃៈ ។

**មាត្រា ៤៥.** – ការចោទប្រកាន់ក្នុងករណីបទមជ្ឈិម

ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាច :

-បើកការស៊ើបសួរដោយធ្វើដូចដែលបានចែងដោយមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ

-បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចបាន

ចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ឬ

-បង្គាប់ឱ្យនាំជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចដែលបានចែងក្នុងមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) និងមាត្រា ៤៨ (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ ។

**មាត្រា ៤៦.-** ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន :

-អត្តសញ្ញាណនៃជនជាប់ចោទ

-សេចក្តីសង្ខេបនៃអង្គហេតុ

-ឈ្មោះបទល្មើស

-អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

**មាត្រា ៤៧.-** ការបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ :

-បទល្មើសជាបទល្មើសជាក់ស្តែង តាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ

-ជនជាប់ចោទជានីតិជន

-រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

**មាត្រា ៤៨.-** នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ :

-ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន

-ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

**មាត្រា ២៨៤.** – ដីកាបញ្ជូនលិខិត

កាលណាចៅក្រមស៊ើបសួរបញ្ជូនលិខិតណាមួយនៃសំណុំរឿងទៅព្រះរាជអាជ្ញាពិនិត្យ ចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជូនលិខិតនោះ ។

កាលណាចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាពិនិត្យ ចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជូនសំណុំរឿងនោះ ។

បទប្បញ្ញត្តិនៃមាត្រា ២៤៣ (និទ្ទេសដែលត្រូវចុះជាកាតព្វកិច្ចលើដីការបស់ចៅក្រមស៊ើបសួរ) នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះដីកាបញ្ជូន ។

**មាត្រា ២៨៥.** – បណ្តឹងធ្វើឡើងដោយមេធាវី

គ្រប់ពេលដែលក្រមនេះអនុញ្ញាតឱ្យជនត្រូវចោទជូនពាក្យសុំដល់ចៅក្រមស៊ើបសួរ ពាក្យសុំនេះអាចធ្វើបានដោយមេធាវីរបស់ជនត្រូវចោទ ។

គ្រប់ពេលដែលក្រមនេះអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីជូនពាក្យសុំដល់ចៅក្រមស៊ើបសួរ ពាក្យសុំនេះ អាចធ្វើបានដោយមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណី ។

រាល់ពាក្យសុំដោយបុគ្គលដែលស្ថិតនៅក្រៅនីតិវិធីស៊ើបសួរឱ្យប្រគល់សងវត្ថុដែលចាប់យក អាចធ្វើបានដោយមេធាវី ។

## ជំពូកទី ៥
## ការបិទការស៊ើបសួរ

**មាត្រា ២៨៦.** – ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ។

២ (ពីរ) ថ្ងៃ ក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ (ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) នៃក្រមនេះ ។

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង ១ (មួយ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង ។ ថិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង ។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ

# ជំពូកទី ៣
# ការពិភាក្សាដេញដោល
## ផ្នែកទី ១
## សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និងការដឹកនាំសវនាការ

**មាត្រា ៣១៦.-** សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និងភាពសម្ងាត់នៃកិច្ចពិភាក្សាដេញដោល

ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងពេលសវនាការសាធារណៈ ។

ប៉ុន្តែ បើតុលាការយល់ឃើញថាសាធារណភាព បង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ នោះតុលាការតាមសេចក្តីសម្រេចមានសំអាងហេតុ អាចបង្គាប់ឱ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែក ប្រព្រឹត្តទៅជាសម្ងាត់ ។ តុលាការសម្រេចតាមសាលក្រមមួយ ដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលក្រមលើអង្គសេចក្តី ។

សេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់ មិនអាចតវ៉ាបានទេ ។

**មាត្រា ៣១៧.-** ការប្រកាសសាលក្រម

នៅក្នុងគ្រប់ករណីទាំងអស់ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ ។

**មាត្រា ៣១៨.-** ការធានាសណ្តាប់ធ្នាប់នៃសវនាការ

ប្រធានសវនាការដឹកនាំការពិភាក្សាដេញដោល ។ ប្រធានត្រូវរ៉ាប់រងឱ្យសិទ្ធិខាងការការពារបានប្រព្រឹត្តទៅដោយសេរី ។ ប៉ុន្តែ ប្រធានអាចបដិសេធចេញពីការពិភាក្សាដេញដោលនូវអ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលនេះដោយឥតប្រយោជន៍ គ្មានរួមវិភាគទានអ្វីដល់ការសំដែងឱ្យឃើញការពិត ។

ប្រធានសវនាការរ៉ាប់រងឱ្យមានសណ្តាប់ធ្នាប់ល្អនៅពេលសវនាការ ។

ប្រធានសវនាការអាចហាមឃាត់អនីតិជនខ្លះ ឬទាំងអស់មិនឱ្យចូលក្នុងបន្ទប់សវនាការ ។

ប្រធានសវនាការអាចបង្គាប់ឱ្យបណ្តេញបុគ្គលគ្រប់រូប ដែលបង្កឱ្យមានការច្របូកច្របល់ដល់របៀបរៀបរយនៃការពិភាក្សាដេញដោល ។

ក្នុងការបំពេញមុខងាររបស់ខ្លួន ប្រធានសវនាការអាចប្រើប្រាស់កងកម្លាំងសាធារណៈ ។

**មាត្រា ៣១៩.-** ការពិនិត្យមើលសំណុំរឿង

មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ។

មេធាវី ឬលេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឱ្យធ្វើការចម្លងលិខិតនៃសំណុំរឿង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ។

**មាត្រា ៣២០.** – បទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលសវនាការ

ប្រសិនបើមានបទល្មើសបានកើតឡើងនៅក្នុងពេលសវនាការ ប្រធានសវនាការធ្វើកំណត់ហេតុពិនិត្យរឿងហេតុនេះ ។

ប្រធានសវនាការអាចបង្គាប់ឱ្យចាប់ និងនាំជនល្មើសភ្លាមជូនព្រះរាជអាជ្ញា ដើម្បីថ្លឹងថ្លែងពីវិធានការដែលត្រូវចាត់ ។

កាលណាបទល្មើសជាបទលហុ ឬបទមជ្ឈិម តុលាការអាចជំនុំជម្រះជនល្មើសភ្លាម ប្រសិនបើព្រះរាជអាជ្ញាប្ដឹងសុំ និងប្រសិនបើជនល្មើសយល់ព្រម ។

## ផ្នែកទី ២
## វិធាននៃភស្តុតាង

**មាត្រា ៣២១.** – ការវាយតំលៃលើភស្តុតាងដោយតុលាការ

លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី ។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ។

តុលាការសំអាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តែទៅលើភស្តុភាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ។

ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង ។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ ។

ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន មិនអាចយកមកធ្វើជាភស្តុតាងបានឡើយ ។

## ផ្នែកទី ៣
## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

**មាត្រា ៣២២.** – វិធានទាក់ទងនឹងភាគីដែលមានវត្តមាននៅក្នុងសវនាការ

ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ ។

កាលណាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយសហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់ ក្រឡាបញ្ជីពិនិត្យមើលអត្តសញ្ញាណនៃអ្នកតំណាង និងសុពលភាពនៃការប្រគល់សិទ្ធិ ។ ចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ក៏ត្រូវធ្វើដូច្នេះដែរ ។ ក្រឡាបញ្ជីត្រូវសុំយោបល់ប្រធានសវនាការក្នុងករណីចាំបាច់ ។

ភាគីនីមួយៗ អង្គុយនៅតាមកន្លែងដែលទុកសម្រាប់ឱ្យខ្លួន នៅក្នុងបន្ទប់សវនាការ ។

ជនជាប់ចោទមិនត្រូវទាក់ទងនឹងគ្នាទេ ។

អ្នកជំនាញ និងសាក្សីថយខ្លួនទៅនៅក្នុងបន្ទប់រង់ចាំដែលទុកបម្រុងឱ្យខ្លួន ហើយដែលពីក្នុងបន្ទប់រង់ចាំនោះ ខ្លួនមិនអាចមើលឃើញ ឬឮអ្វីដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការទេ ។

នៅក្នុងពេលសវនាការ និងនៅក្នុងបន្ទប់រង់ចាំ សាក្សីមិនត្រូវទាក់ទងនឹងគ្នាទេ ។

**មាត្រា ៣២៣.** – វិវាទកម្មស្តីពីនិយតភាពនៃការកោះហៅ

វិវាទកម្មស្តីពីភាពត្រឹមត្រូវនៃដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៃកំណត់ហេតុចូលបង្ហាញខ្លួនភ្លាម ឬការកោះឱ្យចូលមកបង្ហាញខ្លួននៅពេលសវនាការ ត្រូវតែលើកឡើងនៅមុនពេលសួរចម្លើយជនជាប់ចោទលើអង្គសេចក្តី បើពុំដូច្នោះទេ វិវាទកម្មនេះមិនអាចទទួលបានឡើយ ។

**មាត្រា ៣២៤.** – ការស្តាប់ចម្លើយរបស់សាក្សីដែលមិនត្រូវបានកោះហៅ

នៅពេលបើកពិភាក្សាដេញដោល ភាគីអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែ មិនបានកោះហៅឱ្យបានត្រឹមត្រូវទេ ។ ការស្តាប់ចម្លើយសាក្សីនេះត្រូវមានការយល់ព្រមពីប្រធានសវនាការ ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះឱ្យថយទៅនៅបន្ទប់រង់ចាំ ។

**មាត្រា ៣២៥.** – ការសួរចម្លើយជនជាប់ចោទ

ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទ ឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន និងធ្វើការសួរចម្លើយជនជាប់ចោទនេះ ។ ប្រធានសវនាការសួរគ្រប់សំណួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត ។ ប្រធានសវនាការមាន ករណីយកិច្ចសួរចម្លើយជនជាប់ចោទនេះ ទាំងខាងផ្នែកដាក់បន្ទុក ទាំងខាងផ្នែកដោះបន្ទុក ។

ក្រោយពីប្រធានសវនាការសួរចម្លើយរួចហើយ ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរដល់ជនជាប់ចោទ ។ គ្រប់ការលើកសំណួរទាំងអស់ ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរ

ផ្សេងៗទៀត ត្រូវសួរតាមរយៈប្រធានសវនាការ ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរឬទេ ។

**មាត្រា ៣២៦.– ការស្តាប់ចម្លើយរបស់ភាគី**

ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ ។ ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី ។

ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរ ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរឬទេ ។

**មាត្រា ៣២៧.– ការជំទាស់ទៅនឹងការស្តាប់ចម្លើយរបស់សាក្សី**

ព្រះរាជអាជ្ញា មេធាវី និងភាគី អាចជំទាស់នឹងការស្តាប់សាក្សី ដែលខ្លួនយល់ឃើញថា ចម្លើយនេះគ្មានប្រយោជន៍អ្វីដល់ការសំដែងឱ្យឃើញការពិត ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើត្រូវស្តាប់ ឬមិនស្តាប់ចម្លើយសាក្សីនេះ ។

**មាត្រា ៣២៨.– ការស្បថរបស់សាក្សី**

ប្រធានសវនាការសួរសាក្សីម្នាក់ៗថាតើ ជាញាតិលោហិត ឬញាតិពន្ធរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬក៏ជាអ្នកស៊ីឈ្នួលបម្រើជនទាំងនោះឬទេ ។

មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីនីមួយៗត្រូវស្បថថា ខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន ។

ក្រោយពេលឆ្លើយរួចហើយ សាក្សីនីមួយៗ ត្រូវតែនៅបម្រុងខ្លួនសម្រាប់សេចក្តីត្រូវការរបស់តុលាការ ។ តុលាការអាចអនុញ្ញាតឱ្យសាក្សីនេះថយខ្លួន ប្រសិនបើវត្តមានរបស់សាក្សីនេះលែងចាំបាច់ទៀតហើយ ។

បទប្បញ្ញត្តិនៃមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ។

**មាត្រា ៣២៩.– អ្នកប្តឹងបរិហារ**

អ្នកប្ដឹងបរិហារដែលបានទទួលរង្វាន់ពីបណ្ដឹងបរិហាររបស់ខ្លួន ក៏អាចត្រូវបានតុលាការស្ដាប់ចម្លើយយកជាព័ត៌មានបានដែរ ។

**មាត្រា ៣៣០.** – ជំនួយ និងសម្បថរបស់អ្នកបកប្រែ

ក្នុងករណីចាំបាច់ ប្រធានអាចហៅរកអ្នកបកប្រែ ។ អ្នកបកប្រែនេះត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយដល់តុលាការ និងបកប្រែចម្លើយឱ្យបានស្មោះត្រង់ ។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែ មិនអាចត្រូវបានជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជីនគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីទេ ។

បទប្បញ្ញត្តិនៃមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ។

**មាត្រា ៣៣១.** – ជនគ ថ្លង់

កាលណាសំណួរត្រូវសួរដល់ជនគ ថ្លង់ ក្រឡាបញ្ជីសរសេរសំណួរ ហើយឱ្យសាមីខ្លួនអាន និងឆ្លើយដោយលាយលក្ខណ៍អក្សរ ។ ក្នុងករណីសាមីជនមិនចេះអាន ឬមិនចេះអក្សរ ប្រធានសវនាការ ត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងដោយមាត្រា ៣៣០ (ជំនួយ និងសម្បថរបស់អ្នកបកប្រែ) នៃក្រមនេះ ។

ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជននេះមកបកប្រែ ។ បុគ្គលនេះត្រូវស្បថតាមសាសនា និងជំនឿរបស់ខ្លួនថាជួយតុលាការ និងត្រូវបកប្រែចម្លើយឱ្យបានស្មោះត្រង់ ។

**មាត្រា ៣៣២.** – ការបង្ហាញវត្ថុតាង

ប្រធានសវនាការអាចបង្គាប់ឱ្យជនណាម្នាក់បង្ហាញវត្ថុតាងបាន ។

**មាត្រា ៣៣៣.** – ការស្វែងរកការពិតក្នុងករណីអវត្តមានរបស់ជនជាប់ចោទ

ទោះបីជាជនជាប់ចោទអវត្តមានក៏ដោយ តុលាការត្រូវតែស្វែងរកឱ្យឃើញការពិត ស្ដាប់ចម្លើយភាគីដទៃទៀត សាក្សី និងពិនិត្យវត្ថុតាង ។

**មាត្រា ៣៣៤.** – ការដាក់សេចក្ដីសន្និដ្ឋានរហូតដល់បិទកិច្ចពិភាក្សាដេញដោល

រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត ។

សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ និងក្រឡាបញ្ជី

ហើយត្រូវភ្ជាប់ទៅក្នុងសំណុំរឿង ។

**មាត្រា ៣៣៥.** – សិទ្ធិនិយាយស្ដីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

ក្រោយពិភាក្សាដេញដោល ប្រធានសវនាការបើកឱ្យជនដូចខាងក្រោមនេះនិយាយជាបន្តបន្ទាប់គ្នា :

-ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទ ដើម្បីធ្វើការកត់សំគាល់ខ្លីៗ

-មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ

-ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ

-មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ ។

ដើមបណ្ដឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចឆ្លើយតបទៅវិញបាន ។ ប៉ុន្តែ ជនជាប់ចោទ និងមេធាវីរបស់ខ្លួន ត្រូវនិយាយក្រោយគេបង្អស់ជានិច្ច ។

ការបំពេញទម្រង់ការនេះ ត្រូវតែកត់ត្រាទុកក្នុងកំណត់ហេតុសវនាការ និងក្នុងសាលក្រម ។

**មាត្រា ៣៣៦.** – ពាក្យប្ដឹងសុំដោយផ្ទាល់មាត់របស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាធ្វើការសន្និដ្ឋានប្ដឹងសុំដោយផ្ទាល់មាត់ ដែលខ្លួនយល់ឃើញថា សមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌ ។

**មាត្រា ៣៣៧.** – ការពិភាក្សាសម្រេចរបស់តុលាការ

តុលាការថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាដើម្បីសម្រេច ។ គ្មានបណ្ដឹងសុំណាមួយអាចត្រូវដាក់ជូនតុលាការបានទៀតទេ ។ គ្មានទឡ្ហីករណ៍ណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានឡើយ ។

ព្រះរាជអាជ្ញា និងក្រឡាបញ្ជី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការពិភាក្សាសម្រេចនេះទេ ។

**មាត្រា ៣៣៨.** – ការចុះដល់កន្លែងរបស់តុលាការ

តុលាការអាចចុះទៅកាន់គ្រប់ទីកន្លែងនៃដែនដីជាតិ ក្នុងផលប្រយោជន៍នៃការសម្ដែងឱ្យឃើញការពិត ។

តុលាការត្រូវតែមានព្រះរាជអាជ្ញា និងក្រឡាបញ្ជីអមដំណើរជានិច្ច ។ ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ព្រមទាំងមេធាវី ក៏អាចជូនដំណើរតុលាការបានដែរ ប្រសិនបើខ្លួនបានស្នើសុំ ។

ប្រតិបត្តិការទាំងនេះ ត្រូវតែមានធ្វើកំណត់ហេតុ ។

**មាត្រា ៣៣៩.** – ព័ត៌មានបន្ថែមដែលបង្គាប់ដោយតុលាការ

ប្រសិនបើយល់ឃើញថា ការស្រាវជ្រាវថ្មីជាការចាំបាច់ តុលាការអាចបង្គាប់តាមសាលក្រម ឱ្យធ្វើការស៊ើបសួរបន្ថែម ។

អ្នកដែលមានសមត្ថកិច្ចធ្វើការស៊ើបសួរបន្ថែមនេះគឺ :

-ប្រធានសវនាការ

-ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ កាលណាតុលាការសម្រេចជាក្រុមសមូហភាព

-ចៅក្រមដទៃទៀត នៃតុលាការជាន់ដំបូង ។

សាលក្រមដែលបង្គាប់ធ្វើការស៊ើបសួរបន្ថែម ត្រូវចាត់តាំងចៅក្រមឱ្យទទួលភារកិច្ចនេះ ។

នៅក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ ចៅក្រមនេះអាច :

-ចុះទៅលើគ្រប់វិសាលភាពនៃដែនសមត្ថកិច្ចតុលាការ ឬលើគ្រប់វិសាលភាពនៃដែនដីជាតិ

-ស្តាប់ចម្លើយសាក្សី

-ធ្វើការឆែកឆេរ

-ចាប់យកវត្ថុតាង

-បង្គាប់ឱ្យធ្វើកោសលវិច័យ ។

ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឱ្យសួរជំនួសបានដែរ ។

**មាត្រា ៣៤០.** – រឿងក្តីដែលត្រូវបានដាក់ឱ្យចាត់ការបន្ត

ប្រសិនបើការពិភាក្សាដេញដោលមិនបានបញ្ចប់នៅក្នុងពេលសវនាការនោះទេ តុលាការអាចបន្តនៅពេលសវនាការក្រោយ តាមកាលបរិច្ឆេទដែលខ្លួនកំណត់ ។

**មាត្រា ៣៤១.** – ការសរសេរកំណត់ហេតុសវនាការ

នៅពេលសវនាការ ក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការដែលមានគោលដៅផ្តល់មធ្យោបាយដល់សាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សា ដេញដោល ។

ក្រឡាបញ្ជីត្រូវខិតខំរៀបរាប់ដោយយកចិត្តទុកដាក់អំពីការប្រព្រឹត្តទៅនៃសវនាការ និងកត់ត្រាឱ្យបានត្រឹមត្រូវតាមសំណួរដែលសួរ ព្រមទាំងចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ។

កំណត់ហេតុសវនាការត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការ

ផ្សៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម ។

ក្រឡាបញ្ជីណាដែលខ្ជីខ្ជានៅក្នុងការកាន់កាប់កំណត់ហេតុសវនាការ ត្រូវទទួលទណ្ឌកម្មខាងវិន័យ។

## ផ្នែកទី ៤

## អញ្ញត្រកម្ម

**មាត្រា ៣៨២.** – សមត្ថកិច្ចរបស់តុលាការក្នុងរឿងអញ្ញត្រកម្ម

តុលាការដែលទទួលបណ្ដឹងអាជ្ញា មានសមត្ថកិច្ចដើម្បីសម្រេចអំពីគ្រប់អញ្ញត្រកម្មទាំងអស់ដែលលើកឡើងដោយគូភាគី លើកលែងតែច្បាប់បានបញ្ញត្តផ្សេងពីនេះ ។

តុលាការមានសមត្ថកិច្ច ជាអាទិ៍ ដើម្បីសម្រេចពីអញ្ញត្រកម្ម ស្ដីពីមោឃភាពនៃនីតិវិធីដែលគេដាក់ជូនខ្លួនពិនិត្យ លើកលែងតែកាលណាតុលាការទទួលជំនុំជម្រះតាមដីកាបញ្ជូនពីចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ។

**មាត្រា ៣៨៣.** – បញ្ហាបន្ទាន់បង្គ្រី និងការបង្អង់មិនទាន់សម្រេច

តុលាការត្រូវបង្អង់មិនទាន់សម្រេច កាលណាភាគីណាមួយលើកបញ្ហាបន្ទាន់បង្គ្រីដែលការពិនិត្យបញ្ហានេះជាសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការមួយផ្សេងទៀត ។

បញ្ហាបន្ទាន់បង្គ្រីអាចនឹងទទួលបានលុះត្រាតែបញ្ហានេះ អាចនឹងលុបលាងចរិតជាបទល្មើសពីអំពើដែលចោទប្រកាន់លើជនជាប់ចោទ ។

ក្នុងរឿងរដ្ឋប្បវេណី បញ្ហាស្ដីពីសិទ្ធិខាងកម្មសិទ្ធិ សិទ្ធិប្រត្យក្សលើអចលនវត្ថុ និងឋានៈបុគ្គល ជាសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការរដ្ឋប្បវេណី ។

**មាត្រា ៣៨៤.** – ការបង្ហាញអញ្ញត្រកម្ម

អញ្ញត្រកម្មត្រូវតែលើកឡើងមុនដំណាក់កាលការពារដល់អង្គសេចក្ដី បើពុំដូច្នេះទេពុំអាចទទួលបានឡើយ ។

**មាត្រា ៣៨៥.** – ការទទួលបញ្ហាបន្ទាន់បង្គ្រី

តុលាការអាចប្រកាសថា មិនអាចទទួលបាននូវបញ្ហាបន្ទាន់បង្គ្រីតែតាមសាលក្រមដែលមានសំអាងហេតុប៉ុណ្ណោះ ។ កាលណាអញ្ញត្រកម្មមិនបានទទួលការយល់ព្រមទេ ការពិភាក្សាដេញដោលត្រូវបន្ត ។

កាលណាបញ្ហាបន្ទាន់បង្គ្រីត្រូវបានលើកឡើង និងត្រូវបានទទួលយល់ព្រមដោយតុលាការនោះ តុលាការនេះត្រូវបង្អង់មិនទាន់សម្រេច ហើយកំណត់រយៈពេលឱ្យភាគីពាក់ព័ន្ធប្ដឹងទៅ

តុលាការមានសមត្ថកិច្ច ។

លុះផុតរយៈពេលនេះ ប្រសិនបើភាគីពាក់ព័ន្ធបង្ហាញភស្តុតាងថា បានប្ដឹងតុលាការមានសមត្ថកិច្ចហើយ តុលាការកំណត់រយៈពេលថ្មីមួយទៀត ដើម្បីឱ្យបានសេចក្ដីសម្រេចអំពីបញ្ហានេះ ។ តុលាការដែលទទួលបណ្ដឹង ត្រូវបានទទួលដំណឹងអំពីរយៈពេលនេះពីព្រះរាជអាជ្ញា ។

បើគ្មានសេចក្ដីសម្រេចនៅក្នុងរយៈពេលដែលកំណត់ដោយតុលាការនោះទេ រឿងក្ដីព្រហ្មទណ្ឌចាប់ដំណើរការតទៅទៀត ប្រសិនបើការយឺតយ៉ាវនេះជាកំហុសបណ្ដាលមកពីការធ្វេសប្រហែសរបស់ភាគីពាក់ព័ន្ធ ។

**មាត្រា ៣៨៦.** – ការជំនុំជម្រះលើអញ្ញត្រកម្ម

តុលាការត្រូវសម្រេចអំពីអញ្ញត្រកម្មតាមសាលក្រមមួយដាច់ដោយឡែក ពីសាលក្រមនៃអង្គសេចក្ដី ។

ប៉ុន្តែ តុលាការក៏អាចបញ្ចូលឧបឃ្ញត្តិហេតុទៅនឹងអង្គសេចក្ដី ហើយសម្រេចតាមសាលក្រមតែមួយដូចគ្នា អំពីអញ្ញត្រកម្មជាមួយនឹងអង្គសេចក្ដី ។

## ជំពូកទី ៤
## សេចក្ដីសម្រេច
### ផ្នែកទី ១
### ការប្រកាសសាលក្រម

**មាត្រា ៣៨៧.** – ការប្រកាសសាលក្រម

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ។ នៅក្នុងករណីខាងក្រោយនេះ ប្រធានសវនាការជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាន អំពីថ្ងៃដែលត្រូវប្រកាសសាលក្រម ។

**មាត្រា ៣៨៨.** – ដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះអង្គហេតុ

តុលាការអាចសម្រេចសេចក្ដីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម ។

ក្នុងករណីដែលតុលាការសម្រេចរួមជាក្រុម ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្ដឹងនោះ បង្កើតបានជាបទមជ្ឈិម ឬបទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្ដីដដែល ។

ក្នុងករណីដែលតុលាការសម្រេចដោយមានចៅក្រមតែម្នាក់គត់ ហើយយល់ឃើញថា អង្គហេតុដែលត្រូវបានប្ដឹងនោះ បង្កើតបានជាបទឧក្រិដ្ឋ តុលាការនោះបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ ។

**មាត្រា ៣៤៩.** – ដែននៃការប្ដឹងទៅតុលាការចំពោះបុគ្គល

តុលាការអាចជំនុំជម្រះបុគ្គលដែលបញ្ជូនទៅចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។

ប្រសិនបើបុគ្គលណាដែលកោះហៅឱ្យចូលទៅចំពោះមុខតុលាការក្នុងឋានៈជាសាក្សី អាចត្រូវចោទប្រកាន់ក្នុងឋានៈជាជនដៃដល់ ឬអ្នកសមគំនិត បុគ្គលនោះនឹងអាចត្រូវជំនុំជម្រះបាន ក្រោយពី ត្រូវបានចោទប្រកាន់ដូចមានចែងនៅមាត្រា ៤៣ (ការចោទប្រកាន់) តែប៉ុណ្ណោះ ។

**មាត្រា ៣៥០.** – ការប្រកាសពីពិរុទ្ធភាព

តុលាការពិនិត្យមើលថា :

-អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ

-ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់លើខ្លួនឬទេ ។

ប្រសិនបើពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្ដន្ទាទោសតាមច្បាប់បញ្ញត្តិ ។

ប្រសិនបើតុលាការយល់ឃើញថាអំពីនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ ។

**មាត្រា ៣៥១.** – អវត្តមានរបស់ជនជាប់ចោទ

វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច ។

ក្នុងករណីជនជាប់ចោទអវត្តមាន តុលាការត្រូវប្រកាសទោសដែលយល់ឃើញថាត្រឹមត្រូវ ប្រសិនបើខ្លួនប្រកាសថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះមែន ។

**មាត្រា ៣៥២.** – ការបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបញ្ចប់នៅពេលប្រកាសសាលក្រម ។

**មាត្រា ៣៥៣.** – ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន ចេញដោយតុលាការ

ប្រសិនបើតុលាការប្រកាសផ្ដន្ទាទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទេ តុលាការតាមសេចក្ដីសម្រេចពិសេស និងដោយមានសំអាងហេតុ អាចចេញនៅ

ក្នុងពេលសវនាការ ៖

-ដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន

-ដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទអវត្តមាន ។

ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន មានអានុភាពអនុវត្តភ្លាមៗ ។

ដីកាទាំងនោះមានចុះនិទ្ទេសដូចតទៅ ៖

-អត្តសញ្ញាណរបស់ពិរុទ្ធជន

-ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ដែលជាមូលដ្ឋាននៃការផ្តន្ទាទោសនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកានេះត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមនេះ និងបោះត្រាផង ។

ពិរុទ្ធជនដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួននោះ ត្រូវតែបានគេនាំទៅបង្ហាញខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុតនៅមុខព្រះរាជអាជ្ញា នាទីកន្លែងចាប់ខ្លួនដែលឱ្យដឹងដល់សាមីខ្លួនអំពីដីកានេះ និងធ្វើការឃុំខ្លួន ។

កាលណាសាលក្រមត្រូវបានសម្រេចដោយកំបាំងមុខនោះ ពិរុទ្ធជនដែលសម្រេចចិត្តថាប្តឹងទាស់ ត្រូវតែចូលបង្ហាញខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅមុខតុលាការដែលបានប្រកាសសាលក្រម ។ ពិរុទ្ធជនអាចធ្វើពាក្យសុំនៅក្រៅឃុំ ។ តុលាការត្រូវសម្រេចដូចដែលមានចែងនៅមាត្រា ៣០៧ (បណ្តឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទដែលជាប់ឃុំ) នៃក្រមនេះ ។

**មាត្រា ៣៥៤.** – ការប្រគល់វត្ថុដែលចាប់យក

តុលាការមានសមត្ថកិច្ចសម្រេចអំពីការប្រគល់វត្ថុដែលចាប់យក ។

**មាត្រា ៣៥៥.** – ការសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី

នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ។ តុលាការវិនិច្ឆ័យអំពីភាពអាចទទួលបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅលើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ កាលណាតុលាការមិនទាន់អាចសម្រេចបានលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីទេ តុលាការអាចបង្អង់ទៅសវនាការលើកក្រោយ និងអាចសម្រេចឱ្យប្រាក់បណ្តោះអាសន្ន ។

បុគ្គលដែលត្រូវផ្តន្ទាទោសក្នុងបទល្មើសតែមួយជាមួយគ្នានោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

**មាត្រា ៣៥៦.** – អវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី បានជូនពាក្យសុំទាមទារសំណងការខូចខាតនៅមុនពេលសវនាការ តែអវត្តមាននៅពេលសវនាការ ហើយប្រសិនបើតុលាការប្រកាសថាមានពិរុទ្ធលើជនជាប់ចោទនោះ តុលាការត្រូវតែសម្រេចឱ្យសងការខូចខាតដល់ជនរងគ្រោះដោយផ្អែកលើអត្ថន័យនៃសំណុំរឿង ។

**មាត្រា ៣៥៧.-** ការសរសេរសាលក្រម : ផ្នែកសំអាងហេតុ និងផ្នែកសម្រេច

គ្រប់សាលក្រមត្រូវមានពីរផ្នែក :

-ផ្នែកសំអាងហេតុពោលគឺទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច ។

-ផ្នែកសម្រេចពោលគឺសេចក្តីសម្រេចរបស់តុលាការ ។

អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកនៅពេលសវនាការ ។

នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី ។

ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេស អំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុសអត្ថបទច្បាប់ដែលអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី ។

**មាត្រា ៣៥៨.-** និទ្ទេសដែលត្រូវចុះលើសាលក្រម

សាលក្រមត្រូវចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជី ។

សាលក្រមត្រូវមានចុះសេចក្តីដូចតទៅ :

-កាលបរិច្ឆេទនៃសវនាការ

-កាលបរិច្ឆេទនៃការប្រកាសសាលក្រម

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ

-ឈ្មោះ និងឋានៈតំណាងអយ្យការ

-ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី

-ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

-ឈ្មោះរបស់មេធាវី ។

ក្រោយពីបានចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជីរួច សាលក្រមដើមត្រូវតម្កល់ទុក

ឧបសម្ព័ន្ធ ៣

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :



បុគ្គលដែលបានផ្ដល់តាវកាលិកនោះ មិនអាចទាមទារឱ្យសងតាវកាលិកនោះ មកវិញបាន ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងការអនុវត្តសិទ្ធិទាមទារសំណង របស់បុគ្គលដែលបានផ្ដល់តាវកាលិកនៃការសង ចំពោះកូនបំណុលឡើយ ។

**មាត្រា ៧៤១.-** ការផ្ដល់តាវកាលិកដោយមូលហេតុខុសច្បាប់

នៅក្នុងជំពូកទី ១៥ (សេចក្ដីចម្រើនដោយឥតហេតុ) នេះ ក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតផលប្រយោជន៍ ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងទៅនឹងសណ្ដាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងនោះ ពុំត្រូវបានអនុញ្ញាតឡើយ ។

## ជំពូកទី ១៦
## អំពើអនីត្យានុកូល

**មាត្រា ៧៤២.-** និយមន័យនៃកំហុសចេតនា និង អចេតនា

នៅក្នុងជំពូកទី ១៦ (អំពើអនីត្យានុកូល) នេះ អំពើដោយមានកំហុសចេតនា ឬ អចេតនា សំដៅទៅលើ អំពើដែលត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :

ក-ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ ។

ខ-ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។

**មាត្រា ៧៤៣.-** ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យា-នុកូលទូទៅ

១-បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលកើតឡើងដោយអំពើនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ ។

៣-ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និង ការកើតឡើងនៃការខូចខាត និង ការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត ។

**មាត្រា ៧៤៤.-** សំណងនៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

បុគ្គលដែលទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រា ៧៤៣ (ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ) ខាងលើនេះ ត្រូវសងការខូចខាតចំពោះអ្វីដែលមិនមែនជាទ្រព្យសម្បត្តិផងដែរ ។

**មាត្រា ៧៤៥.-** អសមត្ថភាពក្នុងការទទួលខុសត្រូវ

១-ជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ ។

២-បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលស្ថានភាពនោះបណ្ដាលមក ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ។

**មាត្រា ៧៤៦.-** ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ

១-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ឬ បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើង ដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ ។

២-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើង ដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ ។

៣-បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យដែលទទួលខុសត្រូវក្នុងការសងការខូចខាត តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបាន ដោយបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ។

**មាត្រា ៧៤៧.-** ការទទួលខុសត្រូវរបស់និយោជក

១-បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ ។

២-បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ ។

៣-និយោជក ឬ អ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបាន ដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ ។

**មាត្រា ៧៤៨.–** អំពើអនីត្យានុកូលរបស់នីតិបុគ្គល

១-នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលសមាជិកគណៈកម្មការនាយក ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច ។

២-បើបានសងការខូចខាតតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូចខាតនោះ ។

**មាត្រា ៧៤៩.–** អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

១-បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬ ស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផល មានភាពធ្ងន់ធ្ងរ រដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន ។

**មាត្រា ៧៥០.–** ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

បុគ្គលដែលកាន់កាប់សត្វ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដល់អ្នកដទៃ ដោយសត្វដែលខ្លួនកាន់កាប់ ។

**មាត្រា ៧៥១.–** ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

១-ក្នុងករណីដែលមានវិការៈនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផលក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្ដាល ឱ្យមានការខូចខាតដល់អ្នកដទៃដោយវិការៈនោះ ផលិតករនៃចលនវត្ថុនោះត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រ នៃបច្ចេកទេស ដែលមាននៅសម័យដែលផលិតនោះ ។

២-អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ក្នុងនាមជាផលិតករផងដែរ ។

៣-ក្នុងខ្លឹមសារនៃមាត្រានេះ ចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ ។

៤-ក្នុងខ្លឹមសារនៃមាត្រានេះ បុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬ អ្នកលក់ នៅលើចលនវត្ថុ ត្រូវចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ ។

**មាត្រា ៧៥២.-** ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់

បុគ្គលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការខូចខាតនោះកើតមានឡើងបណ្តាលមកពីប្រធានសក្តិ ឬ ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់គ្មានវិការៈ ហើយការខូចខាតបានកើតឡើង ដោយសារអំពើរបស់ជនរងគ្រោះ ឬ តតិយជន ។

**មាត្រា ៧៥៣.-** ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

១-ក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬ ការគ្រប់គ្រងសំណង់នោះ មានវិការៈ ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និង កម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវបាន ។

២-បន្ទុករបស់កម្មសិទ្ធិករនៃសំណង់ដែលជាប់នឹងដី និង អ្នកគ្រប់គ្រងសំណង់នោះ ត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឱ្យមានវិការៈ នៃការសាងសង់ ឬ ការគ្រប់គ្រង ។

**មាត្រា ៧៥៤.–** អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

**មាត្រា ៧៥៥.–** និយមន័យនៃការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

១-អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើវិលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

**មាត្រា ៧៥៦.–** មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការ

យល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់ ពីសំណាក់អ្នករងគ្រោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់នោះមិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល ។

២-ចំពោះការខូចខាតដែលកើតមានឡើងដោយសារអំពើការពារជាចម្បាន្នរូប ឬ អំពើដោយសារស្ថានភាពចាំបាច់ អ្នកដែលបានប្រព្រឹត្តអំពើការពារ ឬ អំពើដោយសារស្ថានភាពចាំបាច់ ពុំត្រូវទទួលខុសត្រូវឡើយ ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះ ត្រូវទទួលខុសត្រូវ ។

៣-ចំពោះការខូចខាតដោយសារអំពើដែលត្រូវសង្គមទទួលស្គាល់ថា សមហេតុផល អ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ ។

**មាត្រា ៧៥៧.-** គោលការណ៍សងការខូចខាតជាប្រាក់ និង ករណីលើកលែង

១-ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់ ។

២-ក្នុងករណីដែលមិនអាចទទួលការសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារឱ្យធ្វើបដិទាន ឬ អាចទាមទារឱ្យហាមឃាត់មិនឱ្យធ្វើអំពើណាមួយបាន ។

៣-ចំពោះការបរិហារកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈបាន ។

**មាត្រា ៧៥៨.-** ការគណនាចំនួនទឹកប្រាក់នៃការខូចខាត

១-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិដោយសារអំពើអនីត្យានុកូល ភាពខុសគ្នារវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មតថា នឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និង ស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែង ក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃ ដោយប្រើប្រាស់នូវស្ថិតិ និង ឯកសារផ្សេងទៀត ។

២-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតសតិអារម្មណ៍ដោយសារអំពើ

អនីត្យានុកូល ចំនួនទឹកប្រាក់នៃជម្ងឺចិត្ត ត្រូវបានវាយតម្លៃ ដោយគិតពិចារណានូវស្ថានភាពផ្សេងៗ ដូចជាកម្រិតនៃកំហុសចេតនា ឬ អចេតនារបស់អ្នកប្រព្រឹត្តអំពើបំពាន ប្រភេទ និង កម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្តអំពើបំពាននៅក្រោយអំពើបង្កឱ្យមានការរងគ្រោះនោះ ។

**មាត្រា ៧៥៩.–** ការទាមទារសំណងនៃការខូចខាតដោយសារការបាក់បែកវត្ថុ

នៅពេលដែលវត្ថុបានបាក់បែក ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទាមទារសំណង ដូចជាតម្លៃនៃវត្ថុដែលបាក់បែក ឬ សោហ៊ុយជួសជុលវត្ថុនោះ ជាអាទិ៍ ។

**មាត្រា ៧៦០.–** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើជីវិត

១-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទទួលសិទ្ធិទាមទារសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន រហូតដល់មរណភាព ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាល និង សោហ៊ុយចំណាយផ្សេងទៀតដែលជនរងគ្រោះបានបង់ ឬ មានករណីយកិច្ចត្រូវបង់ ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ប្រាក់ចំណូលដែលជនរងគ្រោះមិនបានទទួល ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ជាអាទិ៍ ។

២-បើបុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច ដោយច្បាប់ ទំនៀមទំលាប់ ឬ ដោយកិច្ចសន្យា បានទទួលមរណភាព ដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្តិ អាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះ ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នេះ ត្រូវរួមបញ្ចូលទាំងប្រាក់ជីវព្រឹត្តិដែលបុគ្គលដែលទទួលជីវព្រឹត្តិលែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសព ជាអាទិ៍ ។

៣-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅ

ក្នុង ១ (មួយ) ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណង នៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន ។

**មាត្រា ៧៦១.-** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើរូបរាងកាយ

បើមានការបំពានលើរូបរាងកាយ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាលដែលបានចំណាយហើយ ឬ សោហ៊ុយព្យាបាលដែលប្រមាណថានឹងត្រូវចំណាយនាពេលអនាគត ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល និង ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាល ជាអាទិ៍ ។ ការខូចខាតដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និង ពេលអនាគត ជាអាទិ៍ ។

**មាត្រា ៧៦២.-** ការទាមទារសំណងនៃការខូចខាតផ្នែកសតិអារម្មណ៍ដោយសារការបរិហារកេរ្តិ៍

បើមានការបរិហារកេរ្តិ៍ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ ដោយសារការអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម ។

**មាត្រា ៧៦៣.-** ការទូទាត់ប្រាក់ចំណេញ និង ខាត

ប្រសិនបើជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល ចំនួនប្រាក់ចំណេញនោះត្រូវដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

**មាត្រា ៧៦៤.-** ការទូទាត់នូវកំហុស

បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬរីករាលដាលនៃការខូចខាត តុលាការ

អាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

**មាត្រា ៧៦៥.-** អាជ្ញាយុកាលនៃការរំលត់

សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថា អាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល ១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង ។

**ឧបសម្ព័ន្ធ ៥**

## អ្នកដឹកជញ្ជូន ផ្ទុះការវាយតប់គ្នាជាមួយភ្ញៀវ

នៅវេលាម៉ោង ៩ និង៣០នាទីយប់ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១

សារព័ត៌មាន ខេ ប៊ី អិន

**ក្រុងព្រះសីហនុ៖** គ្រាន់តែខ្វះលុយ២០០រៀល កើតជាជម្លោះ ទាស់សម្តី រវាងស្រ្តីភេទី៣ និងអ្នកដឹកជញ្ជូនអាហារ ក្លាយជាហិង្សារ ឈានទៅដល់ការ ដោះស្បែកជើងវាយក្បាល និងប្រទាញប្រទង់ រហូតរបូតសម្លៀកបំពាក់ ផ្អើលពេញផ្លូវ នៅវេលាម៉ោង ៩ និង៣០នាទីយប់ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ទីតាំងស្ថិតនៅតាមបណ្តោយផ្លូវ ឯករាជ្យ (ជិតតុលាការចាស់)ស្ថិតក្នុងសង្កាត់៤ ខេត្តព្រះសីហនុ។




ជុំវិញករណីខាងលើនេះសមត្ថកិច្ចប៉ុស្តិ៍សង្កាត់៤បានចុះធ្វើការអន្តរាគមនិងធ្វើការឃាត់ខ្លួនភាគីទាំងសងខាង ដោយបច្ចុប្បន្ន បញ្ជូនទៅកាន់ ប៉ុស្តិ៍សង្កាត់៤ ដើម្បីធ្វើការសម្របសម្រួលគ្នា ទៅតាមនីតិវិធីច្បាប់ផងដែរ ៕

**ឧបសម្ព័ន្ធ ៥**

## ខឹងគេដុតរោងរបស់ខ្លួនទៅវាយ២ដៃ ត្រូវគេវាយតបវិញរបួសទាំងប្ដីនឹងប្រពន្ធ

ចេញផ្សាយថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧

សារព័ត៌មានសន្តិសុខសង្គម CTV8

មានការភ្ញាក់ផ្អើលមួយបានកើតឡើង  ខណៈបុរស់ម្នាក់បានប្រើអំពើហឹង្សាវាយបុរស់ម្នាក់ទៀតចំពីដៃ  ដោយខឹងគេដុតរោងខ្លួន។ ហេតុការណ៍នេះបានកើតឡើង វេលាម៉ោង១៩.០០នាទីយប់ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ នៅចំណុចភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។




លោកអធិការស្រុកបានបន្តថា៖ នៅមុនពេលកើតហេតុដោយ ឈ្មោះ ជឹម អ៊ុក និង ហេង ប៊ុនធឿន មានទំនាស់ពាក្យ ដែលគូទំនាស់បានទាស់សំដីជាមួយគ្នា បន្ទាប់មកឈ្មោះ ហេង ប៊ុនធឿន បានវ៉ៃ ឈ្មោះ ជឹម អ៊ុក ចំនួន ០២ដៃ ចំក្បាល់លុះដល់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង១៥.០០នាទី ឈ្មោះ ហេង ប៊ុនធឿន ដែលជាគូទំនាស់មួយគ្នានោះបានចោទថាឈ្មោះ ជឹម អ៊ុក បានដុតរោងខ្លួន បន្ទាប់ ហេង ប៊ុន ធឿន ក៏ដើចូលវាយទៅលើឈ្មោះ ជឹម អ៊ុក ជាច្រើនដៃចំមុខបណ្ដាលឲ្យមានរបួសលើផ្ទៃមុខ ។




លុះដល់ម៉ោង ១៩.០០នាទីនាថ្ងៃដដែល ឈ្មោះ ជឹម អ៊ុក បានទៅយកកាំបិតខ្វែងពីផ្ទះ ខ្លួនដើរសំដៅទៅកាប់លើឈ្មោះ ហេង ប៊ុនធឿន ចំករដៃស្តាំ បណ្តាលឲ្យមានរបួស ឃើញដូចនេះ ឈ្មោះ ចៃតថា (ប្រពន្ធ)របស់ឈ្មោះ ហេង ប៊ុននធឿន បានចូលទៅឃាត់តែត្រូវ ជឹម អ៊ុក កាប់ត្រូវកំពួនដៃខាងស្តាំបណ្តាលឲ្យរបួស ។ បន្ទាប់មកជនរងគ្រោះ បានទៅដាក់បណ្តឹងប៉ុស្តិ៍នគបាលវិហារសួគ៌ ចុះមកអន្តរាគមន៍ និងរកយុត្តិធម៌ យោងតាមពាក្យបណ្តឹងសមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ ជឹម អ៊ុក បញ្ជូនមកអធិការដ្ឋាននគរបាលស្រុកបន្តអនុវត្តតាមនីតិវិធី ៕



**ឧបសម្ព័ន្ធ ៦**

## មន្ត្រីនគរបាលដែលបាញ់ជនបែកថ្នាំកាន់កាំបិតដេញចាក់ខ្លួន នៅមុខធនាគារ ABA

សារព័ត៌មាន freshnewsasia

ចុះផ្សាយនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១

(ភ្នំពេញ)៖ មន្ត្រីនគរបាលដែលយាមនៅធនាគារ ABA ក្រោមស្ពានអាកាសផ្សារដើមហុយ ស្ថិតក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលបាញ់ជនបែកថ្នាំកាន់កាំបិតដេញចាក់ខ្លួន បណ្តាលឲ្យស្លាប់ក្នុងថ្លុកឈាមនោះ នឹងត្រូវបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១នេះដើម្បីបន្តនីតិវិធី។





មន្ត្រីនគរបាលដែលបាញ់ជនបែកថ្នាំម្នាក់ ដើម្បីការពារខ្លួនពីការចាក់ប្រហារនោះ ត្រូវបានគេស្គាល់ឈ្មោះ គឿន ភិរៈ អាយុ៣៦ឆ្នាំ បម្រើការងារនៅអង្គភាពតម្រួតបទបញ្ជា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ប៉ុន្តែដោយសារពេលយប់ទំនេរទើប ទៅបម្រើការងារជាសន្តិសុខយាមធនាគារ ABA ដែលជាកន្លែងកើតហេតុ កាលពីយប់ថ្ងៃទី០៦ ខែមេសា ម្សិលមិញ។



មន្ត្រីនគរបាលជាន់ខ្ពស់ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានប្រាប់បណ្តាញព័ត៌មាន Fresh News ឲ្យដឹងនៅយប់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១នេះថា នគរបាលនោះនឹងត្រូវបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ នៅព្រឹកស្អែក ដើម្បីបន្តនីតិវិធីតាមផ្លូវច្បាប់។ ប៉ុន្តែក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ ក៏ទទួលស្គាល់ថា ការផ្ទុះអាវុធរបស់នគរបាលកាលពីយប់មិញ ទៅលើជនបែកថ្នាំនោះ គឺជាសិទ្ធិការពារខ្លួនដែលធានាដោយច្បាប់។